៧៣- អនុសេនីយ៍ឯក អ៊ុយ សុញ្ញាតិ អត្តលេខ **៦៤២០៦**

៧៤- អនុសេនីយ៍ឯក ជុំ សុខជា អត្តលេខ **២១៦០៩**

៧៥- អនុសេនីយ៍ឯក នង សុខឈី អត្តលេខ **៩៦១៩២**

៧៦- អនុសេនីយ៍ឯក គីម ចាន់ទាសនា អត្តលេខ **៦៦០០២**

៧៧- អនុសេនីយ៍ឯក លី កូឡា អត្តលេខ **៦៤២១៥**

៧៨- អនុសេនីយ៍ឯក អន សុផា អត្តលេខ **៦២០២២**

៧៩- អនុសេនីយ៍ឯក សយ សម្បត្តិ អត្តលេខ **៦៤១៧០**

៨០- អនុសេនីយ៍ឯក អ៊ុយ សម្ផស្ស អត្តលេខ **៦៤១៨៩**

៨១- អនុសេនីយ៍ទោ ជា សេរីសុជាតិ អត្តលេខ **៦៦៩៨១**

៨២- អនុសេនីយ៍ត្រី ផាន់ ចាន់ណារ៉ា អត្តលេខ **៦២០០២**

៨៣- អនុសេនីយ៍ទោ សៀង មុន្នីរ័ត្ន អត្តលេខ **៦៦៩៧៥**

៨៤- អនុសេនីយ៍ទោ ម៉ុល សុខា អត្តលេខ **៤៧០៣៦**

៨៥- អនុសេនីយ៍ត្រី ញៀម ដូរ៉េ អត្តលេខ **៦៤២១៧**

៨៦- អនុសេនីយ៍ត្រី លី រតនៈ អត្តលេខ **៦២០៣០**

គ- មេដាយសិរីវឌ្ឍការពារ ជូន :

១- វរសេនីយ៍ទោ ហេង វណ្ណឌី អត្តលេខ **១៣០៣៥**

២- វរសេនីយ៍ត្រី សាមិទ្ធ មិថុនា អត្តលេខ **៥៦៩៧៨**

៣- វរសេនីយ៍ត្រី ត្រាច ដារិទ្ធ អត្តលេខ **៤៩៨១០**

៤- វរសេនីយ៍ត្រី ជឹម រស្មី អត្តលេខ **២០៤៧៧**

៥- លោកស្រីវរសេនីយ៍ត្រី សុខ ណា អត្តលេខ **២០៤៣៤**

៦- លោកស្រីវរសេនីយ៍ត្រី សាង លាងហ៊ាន់ អត្តលេខ **៣១៤៣០**

៧- លោកស្រីវរសេនីយ៍ត្រី អ៊ុក សុត អត្តលេខ **៥៨៧៣**

៨- វរសេនីយ៍ត្រី សុខ សាធ អត្តលេខ **១៦០២៦**

៩- វរសេនីយ៍ត្រី ម៉ុន ឈី អត្តលេខ **២០៤២៩**

១០- លោកស្រីវរសេនីយ៍ត្រី សម ដារ៉ា អត្តលេខ **៣១៤១១**

១១- លោកស្រីវរសេនីយ៍ត្រី អ៊ុក សុរិយា អត្តលេខ **៣១៣៨១**

១២- វរសេនីយ៍ត្រី ម៉ិច បឿន អត្តលេខ **០២៩៦៤**

១៣- វរសេនីយ៍ត្រី	ស៊ិន ស៊ឹម	អត្តលេខ ០៥៨៦២
១៤- អនុសេនីយ៍ឯក	ទ៊ិន មល្លា	អត្តលេខ ៦៤១៩២
១៥- អនុសេនីយ៍ឯក	ឃ្លោក វឌ្ឍនា	អត្តលេខ ៣៩១២២
១៦- អនុសេនីយ៍ឯក	ឆោម សុវណ្ណ	អត្តលេខ ៥២៥៨១
១៧- អនុសេនីយ៍ឯក	យ៉ាន់ លីមស្រ៊ាន់	អត្តលេខ ៦៤១៧៧
១៨- អនុសេនីយ៍ឯក	ខ្មៀម សា	អត្តលេខ ៦៤១៨៨
១៩- អនុសេនីយ៍ឯក	ម៉ែន វុឌ្ឍី	អត្តលេខ ៦៤១៧៥
២០- អនុសេនីយ៍ទោ	អ៊ឹម សុខជា	អត្តលេខ ៥៧២៥២
២១- លោកស្រីអនុសេនីយ៍ឯក	មាន សុផល	អត្តលេខ ៣១៤២៥
២២- អនុសេនីយ៍ទោ	ម៉ែន សុធន់	អត្តលេខ ៥៦៦៧៥
២៣- អនុសេនីយ៍ទោ	ឡុង ពុទ្ធិជាតិ	អត្តលេខ ៦៦៥៤៧
២៤- អនុសេនីយ៍ទោ	ហេង ទីរី	អត្តលេខ ៦៤១៧៣
២៥- អនុសេនីយ៍ត្រី	យិត ឧត្តម	អត្តលេខ ៦៣៩៥២
២៦- អនុសេនីយ៍ត្រី	អៀម វិត្យា	អត្តលេខ ៥៨១៧០
២៧- ព្រិន្ទបាលឯក	ឈី ជំរាវុធ	អត្តលេខ ៦២០៣៣

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការព្រឹទ្ធសភា
- អគ្គលេខាធិការរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៣៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសាស្ត្រាចារ្យនិង នាយនគរបាលជាតិ ចំនួន ៣៦ រូប ដែលមានស្នាដៃក្នុងការ បំពេញភារកិច្ចជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :

ក.- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ជូន :

១- វរៈសេនីយ៍ទោ **ពៅ ឌីទី**
២- អនុសេនីយ៍ទោ **ឈិត សុខហ៊ាង**
៣- អនុសេនីយ៍ទោ **ហម ធីរ៉េត**
៤- លោកបណ្ឌិត **សុក គន្ធី**
៥- លោកបណ្ឌិត **ចំន្ទ តារាស្មី**
៦- លោកស្រីបណ្ឌិត **ទ្រាំ ទេវី**
៧- លោក **គង់ ប៊ុនធី**
៨- លោក **មូល ស៊ុយហេង**
៩- លោក **ឡុង សារិន**
១០- លោក **លី ឡា**
១១- លោក **អ៊ីវ សៅសុខា**

១២- លោក លី គឹមស៊ាង
១៣- លោក ស្រ៊ុន ហួរ
១៤-លោក អ៊ុល វន
១៥-លោក ឌួច ស្រែង

ខ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ សេនា ជូន :

១- លោក មាស សំអុល
២- លោក លន លីណា
៣-លោក ម៉េង គឹមលី
៤- លោក អ៊ូ សុគ័ណ្ណរ៉ា
៥- លោក ចៅ លីន
៦- លោក ម៉ាន់ ចុន្ថា
៧- លោក អាត់ ចន្ថា
៨- លោក គង់ ធន់
៩- លោក ឡាច ចន្ថា
១០- លោក ឃឿន សុផុន
១១- លោក ពៅ វណ្ណនី
១២- លោក ឌួង ទ្រី
១៣- លោកស្រី សាម សុគន្ធទ្រី
១៤- កញ្ញា ឡេង ស៊ុនសាឡាវី
១៥- កញ្ញា ឆាត ឡេងចាន់ឆាយ៉ា
១៦- លោក សាន សុធន
១៧- លោក ធន សុខឃុយ
១៨- លោក សុខ សុខសាន្ត

គ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ ជូន :

១- អនុសេនីយ៍ឯក ម៉ុំ មិន
២- អនុសេនីយ៍ឯក ពេជ្រ សោភ័ណ្ឌ
៣- អនុសេនីយ៍ទោ គង់ ថារិន

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១០

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការព្រឹទ្ធសភា
-អគ្គលេខាធិការរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៣៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយ សហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ .

ត្រូវបានបំពាក់មេដាយ **សហមេត្រី** តាមលំដាប់ថ្នាក់ជូនដល់គ្រូឧទ្ទេសនាមចំនួន ០៣ នាក់ មកពីការិយាល័យសហព័ន្ធស៊ើបអង្កេត (FBI) សហរដ្ឋអាមេរិក និងភ្នាក់ងារឧទ្យានជាតិសហរដ្ឋអាមេរិក ដែលមានស្នាដៃយ៉ាងធំធេង ខិតខំប្រឹងប្រែងយកអស់កំលាំងកាយចិត្ត ជួយឧបត្ថម្ភដល់កិច្ចកសាងធនធានមនុស្សក្នុងកងកំលាំងនគរបាលជាតិ នូវវគ្គបណ្តុះបណ្តាលជំនាញស៊ើបអង្កេត ឧក្រិដ្ឋកម្មបេតិកភណ្ឌវប្បធម៌ ជូនមន្ត្រីនគរបាលការពារបេតិកភណ្ឌ ព្រមទាំងបានជួយឧបត្ថម្ភសំភារៈកុំព្យូទ័រចំនួន ១០ កំប្លេ ម៉ាស៊ីនថតចំនួន ០៦ គ្រឿង ម៉ាស៊ីនហ្វូតូកូពីចំនួន ០១ គ្រឿង និង LCD ចំនួន ១០ គ្រឿង ដូចមានរាយនាមខាងក្រោម ៖

ក-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ធិបឌិន្ទ ៖

- Mrs. Bonni Magness-Gardiner ប្រធានគ្រប់គ្រងគំរោងបទល្មើសសម្បត្តិវប្បធម៌ ប្រចាំ FBI

ខ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់សេនា ៖

១ Mr.	Todd	Swain	គ្រូឧទ្ទេសនាម ភ្នាក់ងារឧទ្យានជាតិសហរដ្ឋអាមេរិក
២ Mr.	David	Bass	គ្រូឧទ្ទេសនាម ភ្នាក់ងារ FBI

មាត្រា ២ ៈ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៣៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី ៤ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីការកែសំរួល អនុក្រឹត្យលេខ ៥២ អនក្រ.បក ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ១១៥២ អនក្រ.តត ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាល នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៤
- យោងតាមសំណើរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ស ម្រេ ច

មាត្រា ១: ត្រូវបានតែងតាំងឯកឧត្តម **សុខ ហេង** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាសមាជិកក្រុមប្រឹក្សាភិបាល អាណត្តិទី៤ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញជំនួសលោក **ហុង ស៊ីលីន** ដែលបានទទួលមរណ ភាព។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៧.សរ ណន

សារាចរណែនាំ

ស្តីពី

ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១

I. បរិការណ៍នៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១

ក- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

១- បន្ទាប់ពីមានកំណើនខ្ពស់រយៈពេលមួយទសវត្សរ៍ និងកាត់បន្ថយបាននូវអត្រាភាពក្រីក្រគួរឱ្យកត់សម្គាល់មក សេដ្ឋកិច្ចកម្ពុជាត្រូវទទួលរងនូវផលប៉ះពាល់នៃវិបត្តិគលិយុគហិរញ្ញវត្ថុអន្តរជាតិ និងឌិនភាពសេដ្ឋកិច្ចសកលលោក ហើយបានជះឥទ្ធិពលយ៉ាងខ្លាំងដល់រចនាសម្ព័ន្ធសេដ្ឋកិច្ច ដែលទើបបានចាប់ផ្តើមវិវត្តផ្លាស់ប្តូរទៅរកដំណាក់កាលនៃការអភិវឌ្ឍមួយខ្ពស់ជាងមុន តាមរយៈការឆ្លុះបញ្ចាំងពីកំណើនឡើងជាលំដាប់នៃសមាមាត្រវិស័យឧស្សាហកម្ម និងសេវាកម្ម ធៀបនឹងកសិកម្មនៅក្នុងរចនាសម្ព័ន្ធនៃផលិតផលក្នុងស្រុកសរុប (ផសស) ។ ប្រការនេះ បានធ្វើឱ្យការរួមចំណែកនៃវិស័យ ឧស្សាហកម្មធ្លាក់ចុះមកនៅត្រឹមប្រមាណ ២២% ក្នុងឆ្នាំ ២០០៨-២០០៩ បន្ទាប់ពីបានឡើងដល់ប្រមាណជាង ២៩% ក្នុងឆ្នាំ ២០០៦-២០០៧ ហើយវិស័យកសិកម្មបានឡើងដល់ប្រមាណជាង ៣៣% វិញ បន្ទាប់ពីធ្លាក់ចុះ មកនៅត្រឹមប្រមាណ ៣០% ក្នុងឆ្នាំ ២០០៦-២០០៧ ក្នុងពេលដែលវិស័យសេវាកម្មនៅរក្សាបានក្នុងកម្រិត ប្រមាណជិត ៤០% ។ ដូច្នេះ វិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទមិនត្រឹមតែនៅជាមូលដ្ឋានសំខាន់ និងចាំបាច់សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាប៉ុណ្ណោះទេ ថែមទាំងជាមូលដ្ឋានចាំបាច់ និងមិនអាចខ្វះបានសម្រាប់ការពង្រីកមូលដ្ឋានសេដ្ឋកិច្ចផង ព្រមទាំងអាចជួយសង្គ្រោះ និងសម្រាលឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចសាកលលោកប្រកបដោយភាពស័ក្តិសិទ្ធិថែមទៀតផង ។ ប្រការនេះ កាន់តែបញ្ជាក់ឱ្យឃើញថា ការបង្កើនទិន្នផល និងផលិតភាពកសិកម្ម ការធ្វើពិពិធភាវូបនីយកម្មមូលដ្ឋាននៃកំណើនវិស័យកសិកម្ម និងការជំរុញការអភិវឌ្ឍកសិឧស្សាហកម្ម ព្រមទាំងសហគ្រាសធុនតូច និងមធ្យម នៅតែជាយុទ្ធសាស្ត្រដ៏សំខាន់ និងចាំបាច់ ក្នុងការបង្កើនតម្លៃបន្ថែមលើផលិតផលកសិកម្ម និងស្រូបយកពលកម្មដែលចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសពលកម្មដែលត្រូវផ្ទេរចេញពីវិស័យកសិកម្ម និងដើម្បីពង្រីកមូលដ្ឋានកំណើន រក្សាចីរភាព និងសមធម៌នៃកំណើនសេដ្ឋកិច្ច ក្នុងគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ពិសេសនៅជនបទ ស្របតាមគោល-

នយោបាយ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ-បច្ចុប្បន្នកម្ម** ។

២- ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ នេះ ស្ថិតក្នុងបរិការណ៍ ដែលពិភពលោក កំពុងចាប់ផ្តើមជាសះស្បើយតែនៅផុយស្រួយនៅឡើយពីវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងឱនភាពសេដ្ឋកិច្ចសកលលោក ពិសេសនៅក្នុងតំបន់អាស៊ី ហើយដែលបណ្តាប្រទេសភាគច្រើនបាន និងកំពុងពិចារណា និង ស្វែងរកមធ្យោបាយដើម្បីដកគោលនយោបាយវិត្ថារកម្មចំណាយសាធារណៈ ជាបណ្តើរៗ និងដោយប្រុងប្រយ័ត្នខ្ពស់ ដើម្បីផ្តល់ឱកាសដល់វិស័យឯកជនបន្តពង្រឹងសកម្មភាពអាជីវកម្ម របស់ខ្លួន និងឈានជាបណ្តើរៗ ទៅរកស្ថានភាពនៃសេដ្ឋកិច្ចទីផ្សារប្រកបដោយប្រក្រតីភាពឡើងវិញ បន្ទាប់ពី មានការសង្គ្រោះ និងស្រោចស្រង់ស្ថានភាពសេដ្ឋកិច្ចដោយរដ្ឋាភិបាល ។ នៅកម្ពុជា គឺវិស័យឧស្សាហកម្ម និងសេវាកម្ម ដែលត្រូវបានរងនូវការប្រឈមខ្លាំងជាងគេ ពិសេស គឺទីផ្សារនាំចេញសំលៀកបំពាក់ ទីផ្សារអចលនទ្រព្យ សំណង់ និងទេសចរណ៍ ដោយសារការជះឥទ្ធិពលដោយផ្ទាល់នៃ ការធ្លាក់ចុះនូវតម្រូវការ ពីខាងក្រៅ ។

៣- ទោះជាយ៉ាងណា រាជរដ្ឋាភិបាលកម្ពុជាបានទប់ស្កាត់ និងគ្រប់គ្រងវិបត្តិកលិយុគហិរញ្ញវត្ថុ សកលលោក និងឱនភាពសេដ្ឋកិច្ចពិភពលោកបានគួរជាទីមោទនៈ ដែលធ្វើឱ្យកម្ពុជានៅតែរក្សាបាន នូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ តាមរយៈការដាក់ចេញនូវគោលនយោបាយដ៏ត្រឹមត្រូវ សមស្រប និងទាន់ពេលវេលា ការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយសុធន្ទះមោះមុត ការអនុវត្តវិធានការ អភិក្រមសកម្មគ្រប់គ្រង ព្រមទាំងមានយន្តការតាមដានត្រួតពិនិត្យស្ថានភាព និងលទ្ធផលប្រកបដោយ ប្រសិទ្ធភាព ។ ដូច្នេះ ស្ថិតក្នុងស្ថានភាពប្រកបដោយភាពមិនប្រាកដប្រជានៃសកលលោក រាជរដ្ឋាភិបាល នឹងបន្តក្តាប់ និងគ្រប់គ្រងឱ្យខាងតែបាននូវសភាពការណ៍នេះ ដូចដែលរាជរដ្ឋាភិបាលធ្លាប់បានអនុវត្តប្រកប ដោយប្រសិទ្ធភាព ក្នុងរយៈពេលតាំងពីចុងឆ្នាំ ២០០៨ រហូតមកទល់បច្ចុប្បន្ន ។ ជាពិសេស រាជរដ្ឋាភិបាលនឹង បន្តជំរុញការអនុវត្ត និងបន្តដាក់ចេញនូវគោលនយោបាយជាប្រព័ន្ធ ស៊ីសង្វាក់ និងប្រទាក់ក្រឡាគ្នា សំដៅ ពង្រឹងសមិទ្ធិផលជាសន្តិភាព ឯកភាពជាតិ អធិបតេយ្យភាព និងបូរណភាពទឹកដី សន្តិសុខ បន្តធានាស្ថិរភាព នយោបាយសណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងធានាបាននូវការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុ ការគ្រប់គ្រងអតិផរណា ការបង្កើតឡើងនូវបរិស្ថានកាន់តែអនុគ្រោះសម្រាប់សកម្មភាពសេដ្ឋកិច្ច និងធុរកិច្ច ព្រមទាំងការពង្រីង និងពង្រីកនូវប្រព័ន្ធសុវត្ថិភាពសង្គមជូនដល់ប្រជាពលរដ្ឋ ។ ទន្ទឹមនឹងនេះ ផ្អែកលើ សមិទ្ធិផល និងបទពិសោធន៍ដែលរាជរដ្ឋាភិបាលបានកសាងក្នុងរយៈកាលជាង ៣ អាណត្តិកន្លងទៅនេះ ជាពិសេស តាមរយៈការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** រាជរដ្ឋាភិបាលបានបង្កើតនូវមូលដ្ឋានដ៏រឹងមាំសម្រាប់ការបន្តពង្រឹង និងជំរុញការអភិវឌ្ឍ ***ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព*** ដែលជាកត្តាគន្លឹះដ៏សំខាន់បំផុតសម្រាប់សម្រេចឱ្យបានជោគជ័យ នូវយុទ្ធសាស្ត្រ កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

៤- ពិតណាស់ កម្ពុជាបានឆ្លើយតបទៅនឹងវិបត្តិយ៉ាងសកម្មតាមរយៈការធ្វើអន្តរាគមន៍ហិរញ្ញវត្ថុសាធារណៈក្នុងកម្រិតមធ្យមក្នុងទិសដៅរក្សាស្ថិរភាពរូបិយវត្ថុ និងគាំទ្រចីរភាពកំណើនសេដ្ឋកិច្ច ។ នេះគឺដោយសារសេដ្ឋកិច្ចកម្ពុជាមានទំហំតូច និងបើកចំហ ព្រមទាំងមានសេរីភាវូបនីយកម្មគណនីចរន្ត ដែលធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាចំណុះស្ទើរតែទាំងស្រុងទៅលើចីរភាពនៃការពង្រីកពាណិជ្ជកម្មអន្តរជាតិ និងលំហូរចូលនៃមូលធនបរទេស ។ ទោះជាយ៉ាងណា ការចាប់ផ្ដើមងើបឡើងវិញនៃសេដ្ឋកិច្ចក្រោយពីវិបត្តិដ៏ធ្ងន់ធ្ងរនេះ នឹងត្រូវការពេលវេលាមួយសមស្រប ដើម្បីស្ដារស្ថានភាពមករកភាពប្រក្រតី នឹងន និងប្រាកដប្រជាឡើងវិញ ។ម្យ៉ាងទៀត យើងក៏កំពុងប្រឈមមុខនឹងបញ្ហាដ៏ស្រួចស្រាល់មួយ គឺការបោះទីតាំងលើទីផ្សារថ្មីៗបន្ថែមទៀតលើទីផ្សារអាមេរិក និងអឺរ៉ុប ព្រមទាំងការប្រដែងយកប្រភពហិរញ្ញវត្ថុ ទាំងក្នុងទម្រង់ជាហិរញ្ញប្បទានសហប្រតិបត្តិការផ្លូវការ និងការវិនិយោគផ្ទាល់ពីបរទេស ព្រមទាំងពីប្រភពផ្សេងៗទៀត ដើម្បីធ្វើហិរញ្ញប្បទានដល់កំណើន និងការអភិវឌ្ឍរបស់យើង ។ ដូច្នេះ រាជរដ្ឋាភិបាលនឹងបន្តក្ដាប់ឱ្យបាន និងគ្រប់គ្រងឱ្យបាននូវសភាពការណ៍ក្នុងប្រទេស តំបន់ និងសកលលោក ដូចដែលរាជរដ្ឋាភិបាលធ្លាប់បានអនុវត្តប្រកបដោយប្រសិទ្ធភាពកន្លងមក ដោយប្រើគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការ ។

៥- ឆ្នាំ ២០០៩ កន្លងទៅនេះ តាមការគណនាជាបណ្ដោះអាសន្នរបស់វិទ្យាស្ថានជាតិស្ថិតិ កំណើនសេដ្ឋកិច្ចអាចនឹងសម្រេចបានប្រមាណ ០,១% ធៀបនឹងការព្យាករណ៍ ២,១% នៅចុងឆ្នាំក្នុងពេលរៀបចំច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។ ប្រការនេះ គឺដោយសារគ្រោះធម្មជាតិ តែធ្ងន់ជាងនេះគឺដោយសារការរងឥទ្ធិពលអវិជ្ជមានពីខាងក្រៅតាំងពីចុងឆ្នាំ ២០០៨ រហូតមក ដូចជាកត្តាអតិផរណាខ្ពស់ ការធ្លាក់ចុះនូវការនាំចេញសំលៀកបំពាក់ និងចំនួនភ្ញៀវទេសចរ ព្រមទាំងការធ្លាក់ចុះនៃទីផ្សារអចលនទ្រព្យ ដោយសារវិបត្តិទីផ្សារហិរញ្ញវត្ថុអន្តរជាតិ និងឱនភាពសេដ្ឋកិច្ចពិភពលោក ដែលបណ្ដាលឱ្យកំណើនសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាច្រើនមានការធ្លាក់ចុះរហូតដល់ក្រោមសូន្យ ។ សម្រាប់កម្ពុជា លទ្ធផលនៃកំណើនវិជ្ជមាននេះ បានមកដោយសារវិស័យកសិកម្មនៅតែរក្សាបាននូវកំណើន ៥,៤% ធៀបនឹងកំណើន ៥,៧% ក្នុងឆ្នាំ ២០០៨ វិស័យសេវាកម្មរក្សាបាន កំណើនត្រឹម ២,៣% ធៀបនឹងកំណើន ៩% ក្នុងឆ្នាំ ២០០៨ (ដែលក្នុងនោះអាជីវកម្មទេសចរណ៍ បានកើនឡើងប្រមាណ ២,៩% ធៀបនឹង ១០% នៅក្នុងឆ្នាំ ២០០៨) រីឯវិស័យឧស្សាហកម្មបានថយចុះ ៩,៥% ធៀបនឹងកំណើន ៤% ក្នុងឆ្នាំ ២០០៨ (ក្នុងនោះ ផលិតផលវាយនភ័ណ្ឌបានថយចុះ ៩% ធៀបនឹងកំណើន ២,២% ក្នុងឆ្នាំ ២០០៨ និងផលិតផលសំណង់បានកើនឡើង ៥% ធៀបនឹង ៥,៨% ក្នុងឆ្នាំ ២០០៨) ។

៦- តាមការព្យាករណ៍ដោយមានលក្ខណៈប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០១០ នេះ អាចនឹងសម្រេចបានក្នុងរង្វង់ជុំវិញ ៥% ធៀបទៅនឹងការព្យាករណ៍ ៣% នៅក្នុងការរៀបចំច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។ វិស័យកសិកម្មនឹងនៅតែមានកំណើនប្រមាណ ៤% វិស័យឧស្សាហកម្មនឹងមានកំណើនប្រមាណ ១០,៥% ពិសេសដោយសារផលិតផលវាយនភ័ណ្ឌដែលនឹងត្រឡប់មកមានកំណើនប្រមាណ ១,៥% វិញ ផលិតផលសំណង់នឹងនៅបន្តរក្សាបាននូវកំណើនប្រមាណ ២,៦% និង វិស័យសេវាកម្មនឹងបន្តមានកំណើនប្រមាណ៣,៣% ដោយសារអាជីវកម្មទេសចរណ៍អាចនឹងមានកំណើនប្រមាណ៣,៣%។ ស្ថានភាពសេដ្ឋកិច្ចបាន និងកំពុងងើបឡើងវិញដោយសន្សឹមៗ ចាប់តាំងពីចុងឆ្នាំ ២០០៩ មក ពិសេស

លើវិស័យឧស្សាហកម្ម និងសេវាកម្ម ដែលជាវិស័យនៅមានលក្ខណៈផុយស្រួយ និងមានមូលដ្ឋានតូចចង្អៀត ព្រមទាំងនៅពឹងផ្អែកខ្លាំងលើទីផ្សារខាងក្រៅ ។ ស្ថានភាពសេដ្ឋកិច្ចពិភពលោក នៅមានភាពមិនប្រាកដប្រជាខ្ពស់នៅឡើយ ដែលធ្វើឱ្យការព្យាករណ៍លើសូចនាករម៉ាក្រូសេដ្ឋកិច្ចនៅមានការលំបាក និងមានសុក្រឹតភាពទាបនៅឡើយ ។ ដូច្នេះ ការតាមដានត្រួតពិនិត្យជាប្រចាំ និងការត្រៀមលក្ខណៈចាត់វិធានការបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពគឺជាប្រការសំខាន់ ។ ទោះជាយ៉ាងណា ការព្យាករណ៍សូចនាករម៉ាក្រូសេដ្ឋកិច្ចគឺមានភាពចាំបាច់សម្រាប់ការគ្រោងថវិកា និងតម្រង់ទិសចំណូល-ចំណាយ ។ ដូច្នេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តការអប្បមាទ ក្តាប់ជីពចរ និងវាយតម្លៃស្ថានភាពសេដ្ឋកិច្ចជាប្រចាំ ដើម្បីឱ្យការព្យាករណ៍ប្រកបដោយបច្ចុប្បន្នភាព និង អាចជាមូលដ្ឋានប្រកបដោយប្រសិទ្ធភាពសម្រាប់ការគ្រោងថវិកា និងតម្រង់ទិស ចំណូល-ចំណាយ ព្រមទាំងជាមូលដ្ឋានដ៏ស័ក្តិសិទ្ធិសម្រាប់ការលើកអនុសាសន៍ និងវិធានការឱ្យបានទាន់ពេលវេលា ។

៧- ក្នុងឆ្នាំ ២០០៩ កន្លងទៅនេះ អតិផរណាមធ្យមប្រចាំឆ្នាំបានធ្លាក់ចុះរហូតដល់ -0,៦% បន្ទាប់ពីបានកើនឡើងរហូតដល់ ១៩,៧% នៅក្នុងឆ្នាំ ២០០៨ ។ តាមការព្យាករណ៍ អតិផរណាមធ្យមប្រចាំឆ្នាំ ២០១០ នេះ អាចនឹងកើនឡើងតិចតួចពីឆ្នាំ ២០០៩ គឺក្នុងរង្វង់ប្រមាណ ៦% ដោយសារការងើបឡើងវិញ នៃសេដ្ឋកិច្ច និងនិន្នាការកើនឡើងនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារពិភពលោក ។ ដូច្នេះ សម្រាប់ការរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ នេះ កំណើនសេដ្ឋកិច្ចត្រូវបានព្យាករណ៍ក្នុងរង្វង់ ៦% និង អត្រាអតិផរណាជាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៥% ។

ខ- *ស្ថានភាពហិរញ្ញវត្ថុសាធារណៈ និង ថវិកា*

៨- ទោះជាត្រូវបានរងនូវឥទ្ធិពលអវិជ្ជមានពីខាងក្រៅតាំងពីចុងឆ្នាំ ២០០៨ រហូតមក ដូចជាកត្តាអតិផរណាខ្ពស់ ការធ្លាក់ចុះនូវការនាំចេញសំលៀកបំពាក់ និងចំនួនភ្ញៀវទេសចរ ព្រមទាំងការធ្លាក់ចុះនៃទីផ្សារអចលនទ្រព្យ ដោយសារវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងវិបត្តិសេដ្ឋកិច្ចពិភពលោក ដែលបណ្តាលឱ្យកំណើនសេដ្ឋកិច្ចនៃបណ្តាប្រទេសជាច្រើនធ្លាក់ចុះរហូតដល់ក្រោមសូន្យក៏ដោយ ការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពប្រុងប្រយ័ត្នគួបផ្សំនឹងការអនុវត្តគោលនយោបាយរូបិយវត្ថុសមស្រប និង ជាពិសេស ការបន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យ៉ាងមោះមុត គ្រប់ជ្រុងជ្រោយ និងជាជំហានៗ យ៉ាងច្បាស់លាស់ បានធ្វើឱ្យលទ្ធផលកំណើនសេដ្ឋកិច្ច លទ្ធផលវិស័យហិរញ្ញវត្ថុ និងធនាគារ ព្រមទាំងលទ្ធផល នៃការអនុវត្តថវិកាឆ្នាំ ២០០៩ សម្រេចបានគួរជាទីលើកទឹកចិត្ត ។ ជាក់ស្តែង ទោះជាកំណើនសេដ្ឋកិច្ចឆ្នាំ ២០០៩ សម្រេចបានត្រឹម 0,១% ធៀបនឹងការព្យាករណ៍ ២,១% ក៏ដោយ តែកម្ពុជានៅមានកំណើនវិជ្ជមាន ហើយវិស័យហិរញ្ញវត្ថុ និងធនាគារក៏ពុំត្រូវបានប៉ះពាល់ធ្ងន់ធ្ងរដែរ ផ្ទុយទៅវិញ នៅតែបន្តរីកចម្រើនលួតលាស់គួរឱ្យកត់សំគាល់ តាមរយៈការរីកដុះដាលនៃធនាគារពាណិជ្ជ ការកើនឡើងនៃប្រាក់បញ្ញើធនាគារ ការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធ និងសេវាធនាគារ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបាន និងកំពុងជំរុញការពង្រឹង

ការគ្រប់គ្រងធនាគារ ដែលបាន និងកំពុងផ្តល់នូវបុព្វបទជាមូលដ្ឋានចាំបាច់សម្រាប់ការបង្កើតមូលបត្ររដ្ឋ និងមូលបត្រឯកជន ព្រមទាំងទីផ្សារភាគហ៊ុននៅកម្ពុជា ។

៩- ការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ច ពិតជាបានជះឥទ្ធិពលដល់ការអនុវត្តថវិកាឆ្នាំ ២០០៩ ដែលធ្វើឱ្យលទ្ធផលនៃការអនុវត្តចំណូលសម្រេចបានទាបជាងច្បាប់ និងការអនុវត្តឆ្នាំ ២០០៨ កន្លងទៅ ។ ចំណូលក្នុងស្រុកសរុបសម្រេចបាន ៩៤,៦% នៃច្បាប់ គឺថយចុះ ៧,៩% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ហើយស្មើនឹង ១១,៩២% នៃផសស ក្នុងនោះចំណូលសារពើពន្ធសម្រេចបាន ៩៥,៧% នៃច្បាប់ គឺថយចុះ ៧,២% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ហើយស្មើនឹង ១០,១១% នៃផសស និងចំណូលមិនមែនសារពើពន្ធសម្រេចបាន ៩០,៧% នៃច្បាប់ គឺថយចុះ ៦,៣% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ហើយស្មើនឹង ១,៧៥% នៃផសស ។ រីឯការអនុវត្តចំណាយវិញគឺមានកម្រិតខ្ពស់ជាងច្បាប់ និងការអនុវត្តឆ្នាំ ២០០៨ ដោយសារនយោបាយវិត្ថារកម្ម ។ ជាក់ស្តែងចំណាយសរុបឆ្លងកាត់រតនាគារជាតិអនុវត្តបាន ១០៣,៩% នៃច្បាប់ គឺមានកំណើន ២៤,៨% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ហើយស្មើនឹង ១៤,១១% នៃផសស ដែលក្នុងនោះ ចំណាយចរន្តអនុវត្តបាន ១០៧,៧% គឺមានកំណើន ២២,៨% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ហើយស្មើនឹង ១១,៣៥% នៃផសស និង ចំណាយមូលធនសរុបសម្រេចបាន ៩៩,៧% នៃច្បាប់ គឺមានកំណើន ៦,៧% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ហើយស្មើនឹង ៦,៩៦% នៃផសស ដែលក្នុងនោះហិរញ្ញប្បទានក្នុងប្រទេសអនុវត្តបាន ៩០,៦% ធៀបនឹងច្បាប់ គឺមានកំណើន ៣៣,៨% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ស្មើនឹង ២,៧៥% នៃផសស រីឯហិរញ្ញប្បទានក្រៅប្រទេសអនុវត្តបាន ១០៦,៧% ធៀបនឹងច្បាប់ គឺថយចុះ ៥,៩% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ស្មើនឹង ៤,២១% នៃផសស ។ លទ្ធផលនៃការអនុវត្តចំណូល និងចំណាយនេះ បានធ្វើឱ្យមានអតិរេកចរន្តត្រឹមតែ ០,៥០% និងឱនភាពថវិកាសរុបឡើងដល់ ៦,៤០% នៃផសស ។ ទន្ទឹមនឹងនេះ ចំណាយតាមវិស័យដែលអនុវត្តបានគឺ វិស័យរដ្ឋបាលទូទៅសម្រេចបាន ១៤២% នៃច្បាប់ គឺកើនឡើង ៨,១% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ស្មើនឹង ២,០១% នៃផសស វិស័យការពារជាតិ និងសន្តិសុខសម្រេចបាន ១៥៩,៣% នៃច្បាប់ គឺកើនឡើង ៧៥,៤% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ស្មើនឹង ៣,៣១% នៃផសស វិស័យសេដ្ឋកិច្ចសម្រេចបាន ៩៦,៣% គឺថយចុះ ២១,២% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ស្មើនឹង ០,៨១% នៃផសស និងវិស័យសង្គមកិច្ចសម្រេចបាន ១០១,៦% នៃច្បាប់ គឺកើនឡើង ២២,៨% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ស្មើនឹង ៣,៧៧% នៃផសស ។

១០- តាមការព្យាករណ៍ប្រកបដោយភាពប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចឆ្នាំ ២០១០ នេះ អាចនឹងសម្រេចបានរហូតដល់ប្រមាណ ៥% ធៀបនឹង ៣% ដែលបានព្យាករណ៍ក្នុងពេលកសាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។ ទោះជាយ៉ាងណា ការបន្តពង្រឹងការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពត្រឹមត្រូវ និងប្រុងប្រយ័ត្នខ្ពស់ គួបផ្សំជាមួយនឹងការជំរុញការកែលម្អ និងការពង្រឹងការប្រមូល និងការគ្រប់គ្រងចំណូល ការកែលម្អ និងការពង្រឹងការអនុវត្ត និងការគ្រប់គ្រងចំណាយ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ នេះ កាន់តែមានសារៈសំខាន់ និងចាំបាច់ថែមទៀត ដើម្បីធានាឱ្យការអនុវត្តថវិកាឆ្នាំ ២០១០ នេះ សម្រេចបានតាមគោលដៅនៃច្បាប់ហិរញ្ញវត្ថុ ។ តាមការព្យាករណ៍ចំណូលសរុបអាចនឹងសម្រេចបានតាមច្បាប់កំណត់ ហើយ

បើធៀបទៅនឹងការអនុវត្តឆ្នាំ ២០០៩ ចំណូលសរុបអាចនឹងកើនឡើងប្រមាណ ១៤,៥% ដែលក្នុងនោះ ចំណូលក្នុងស្រុកនឹងកើនឡើងប្រមាណ ១៦% (ចំណូលសារពើពន្ធនឹងកើន ១៥,៦% និងចំណូលមិនមែនសារពើពន្ធនឹងកើន ១៦,២%) ។ ចំណូលក្នុងស្រុកសរុបអាចនឹងសម្រេចបានប្រមាណ ១១,៥៦% នៃផសស ដែលក្នុងនោះ ចំណូលសារពើពន្ធនឹងសម្រេចបាន ១០,៦២% នៃផសស (ក្នុងនោះ ចំណូលគយ និងរដ្ឋាករស្មើនឹង ៥,៤៩% និងចំណូលពន្ធដារស្មើនឹង ៤,៣៩%) ចំណូលមិនមែនសារពើពន្ធ នឹងសម្រេចបាន ១,៨៤% នៃផសស ។ ដោយសារ ការបន្តគោលនយោបាយវិត្តារកម្មចំណាយសាធារណៈនៅលើផ្នែកសំខាន់ៗមួយចំនួន ដើម្បីបន្តលើកស្ទួយសកម្មភាពសេដ្ឋកិច្ច និងជំរុញកំណើន ចំណាយសរុបអាចនឹងកើនឡើងដល់ ១៧,៩៦% នៃផសស គឺកើនឡើង ៧,៩% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ដែលក្នុងនោះ ចំណាយចរន្តនឹងកើនដល់ ១០,៩០% នៃផសស គឺកើនឡើង ៥,៦% ធៀបនឹងឆ្នាំ ២០០៩ និង ចំណាយមូលធនសរុបអាចនឹងកើនដល់ ៧,០៦% នៃផសស គឺកើនឡើងប្រមាណ ១១,៦% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ដែលក្នុងនោះហិរញ្ញប្បទានក្នុងប្រទេសអាចកើនដល់ ២,៨៤% នៃផសស គឺមានកំណើន ១៣,៦% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ រីឯហិរញ្ញប្បទានក្រៅប្រទេសអាចកើនដល់ ៤,២២% នៃផសស គឺមានកំណើន ១០,៣% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ។ ការអនុវត្តចំណូល និងចំណាយនេះ អាចនឹងធ្វើឱ្យមានអតិរេកចរន្តប្រមាណ ១,៥៦% នៃផសស និង ឱនភាពថវិកាសរុបប្រមាណ ៥,៤០% នៃផសស ។

II. ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១១

ក. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

១១- សេដ្ឋកិច្ចនៃបណ្តាប្រទេសមួយចំនួន បានចាប់ផ្តើមងើបឡើងវិញជាបណ្តើរៗ តាំងពីចុងឆ្នាំ ២០០៩ មក ហើយការព្យាករណ៍កំណើនសេដ្ឋកិច្ចនៃបណ្តាប្រទេសភាគច្រើនសម្រាប់ឆ្នាំ ២០១០ នេះ ក៏បានបង្ហាញនូវភាពសុទិដ្ឋិនិយមផងដែរ ពិសេសចំពោះបណ្តាប្រទេសនៅអាស៊ី ។ ការវាយតម្លៃ និង សេចក្តីសង្ឃឹមនេះ គឺដោយផ្អែកលើកិច្ចសហការរវាងបណ្តាប្រទេសនៅគ្រប់តំបន់ ដើម្បីចាត់វិធានការដកគោលនយោបាយវិត្តារកម្មចំណាយសាធារណៈជាបណ្តើរៗ និងប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ ក្នុងគោលបំណងផ្តល់ឱកាសដល់វិស័យឯកជនចាប់ផ្តើមពង្រឹង និងពង្រីកសកម្មភាពអាជីវកម្មរបស់ខ្លួនឡើងវិញ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយស្ថិរភាព និងចីរភាព ព្រមទាំងធានាបាននូវសុវត្ថិភាពសង្គម ។ ឈរលើមូលដ្ឋាននេះ កំណើនសេដ្ឋកិច្ចកម្ពុជា ត្រូវបានព្យាករណ៍សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ក្នុងកម្រិត ៦% ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងការតាមដាន និងគ្រប់គ្រងសភាពការណ៍ យ៉ាងហ្មត់ចត់ និងជាប្រចាំ ព្រមទាំងបន្តជំរុញការអនុវត្តប្រកបដោយភាពទន់ភ្លន់ និងបន្តដាក់ចេញនូវវិធានការថ្មីៗទៀត ទៅតាមការវិវត្តនៃស្ថានភាពជាក់ស្តែង ។ ហើយទោះជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាល នៅតែប្រកាន់មហិច្ឆិតាខ្ពស់ ក្នុងការសម្រេចឱ្យបាននូវគោលដៅកំណើនសេដ្ឋកិច្ចប្រមាណ ៧% និងកាត់បន្ថយភាពក្រីក្រឱ្យបានជាង ១% ក្នុងមួយឆ្នាំៗ ស្របតាមគោលដៅនៃយោបាយនៃ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២** និង ការបន្តរក្សាឱ្យបាននូវស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច

ដែលនៅតែជាមូលដ្ឋានគន្លឹះ និងចាំបាច់បំផុត ក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ ***ភាពសុខដុមរមនាសង្គម និងសុខុមាលភាពរបស់ប្រជាជន*** ។

១២- រាជរដ្ឋាភិបាលនៅតែបន្តត្រៀមលក្ខណៈនឹងប្រើវិធានការគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយថវិកា ក្នុងករណីចាំបាច់ ដើម្បីបញ្ចុះ និងគ្រប់គ្រងអត្រាអតិផរណាក្នុងកម្រិតមួយសមស្រប និងដោយប្រុងប្រយ័ត្នបំផុត ដោយធានាកាត់បន្ថយក្នុងកម្រិតអតិបរមានូវផលប៉ះពាល់អាក្រក់លើសេដ្ឋកិច្ចជាតិ និងលើជីវភាពរបស់ប្រជាជន ។ រីឯអត្រាប្តូរប្រាក់ រាជរដ្ឋាភិបាល ក៏នៅតែបន្តត្រៀមនឹងប្រើវិធានការគោលនយោបាយរូបិយវត្ថុ ដើម្បីរក្សាស្ថិរភាព និងកម្រិតមួយសមស្របគឺក្នុងរង្វង់ ៤១០០ រៀល ក្នុង ១ ដុល្លារអាមេរិក ក្នុងទិសដៅធានាឱ្យបាននូវសមត្ថភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា និងធានារក្សាតុល្យភាពរវាងផលប្រយោជន៍អ្នកមានចំណូលជាប្រាក់រៀល និងអ្នកមានចំណូលជាប្រាក់ដុល្លារអាមេរិក ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអភិវឌ្ឍតាមវិស័យ ដែលរួមមាន ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចដែលត្រូវផ្តោតលើកសិកម្ម កសិឧស្សាហកម្ម និងការអភិវឌ្ឍជនបទ ការអភិវឌ្ឍវិស័យសង្គមកិច្ចដែលត្រូវផ្តោតលើការអប់រំ សុខាភិបាល និងការកសាងធនធានមនុស្ស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលត្រូវផ្តោត លើផ្លូវថ្នល់ស្ពាន និងប្រព័ន្ធធារាសាស្ត្រ និងការអភិវឌ្ឍវិស័យឯកជន ។ លើសពីនេះ រាជរដ្ឋាភិបាល នឹងបន្តជំរុញការអនុវត្តបណ្តាកម្មវិធីកែទម្រង់លើគ្រប់វិស័យ ឱ្យបានកាន់តែស៊ីជម្រៅបន្ថែមទៀត ដែលរួមមាន ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ **ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីសម្រេចបាននូវការគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ និងការផ្តល់សេវាសាធារណៈប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ។

ខ- *ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកា*

១៣- ដោយផ្អែកលើមូលដ្ឋាននៃ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ-បច្ចុប្បន្នកម្ម** ជាពិសេស ដើម្បីបម្រើឱ្យការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយអភិវឌ្ឍន៍តាមវិស័យ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ថវិកាឆ្នាំ ២០១១ មានគោលដៅសំខាន់ៗ ដូចតទៅ ÷

- ធានាឱ្យបាននូវការអនុវត្តទិសដៅគោលនយោបាយ និងកម្មវិធីយុទ្ធសាស្ត្រជាអាទិភាពតាមវិស័យ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២** តាមរយៈ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ-បច្ចុប្បន្នកម្ម** ។
- ធានាការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ជាពិសេស ការអភិវឌ្ឍវិស័យអាទិភាព រួមមាន វិស័យសេដ្ឋកិច្ច សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍវិស័យឯកជន ដើម្បីជំរុញកំណើន និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។
- ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល ៣ ឆ្នាំ (២០១១-២០១៣)

• ធានាបម្រើឱ្យការបន្តសកម្មភាពកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលលើគ្រប់ផ្នែក ដែលរួមមាន កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ កំណែទម្រង់វិស័យកងទ័ព និង ការអនុវត្តគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីពង្រឹងអភិបាលកិច្ចល្អ និង បង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពនៃការផ្តល់សេវា សាធារណៈ ។

• ធានាបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់គុណភាពសេវាកម្មនៅក្នុងវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំ សុខាភិបាល និងការកសាងធនធានមនុស្ស ព្រមទាំងធានាបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់សកម្មភាពដែលបម្រើឱ្យវិស័យសេដ្ឋកិច្ច ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការអភិវឌ្ឍជនបទ និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ។

១៤- ដើម្បីសម្រេចបានតាមគោលដៅនៃទិសដៅគោលនយោបាយខាងលើ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តបណ្តាគោលនយោបាយ និងកម្មវិធីកែទម្រង់សំខាន់ៗ ដូចខាងក្រោម៖

ក. បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដ៏ប្រុងប្រយ័ត្ន ភ្ជាប់នឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប ដើម្បីធានាបន្តសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាព ក្នុងបរិការណ៍នៃអត្រាអតិផរណាសមស្រប ។ ជាពិសេស រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្ត ព្រមទាំងបន្តត្រៀមនូវបណ្តាវិធានការគោលនយោបាយថវិកា និងរូបិយវត្ថុសម្រាប់ទប់ទល់នឹងវិបត្តិហិរញ្ញវត្ថុ សេដ្ឋកិច្ច និងអតិផរណា ក្នុងករណីចាំបាច់ ។

ខ. បន្តជំរុញការអភិវឌ្ឍតាមវិស័យ ពិសេស វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ។ ជំរុញ និងបង្កើនការលើកស្ទួយវិស័យកសិកម្ម កសិឧស្សាហកម្ម និងជួយគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម ។ បន្តយកចិត្តទុកដាក់ខ្ពស់លើវិស័យអប់រំ សុខាភិបាល និង ការកសាងធនធានមនុស្ស ។ បន្តជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសប្រព័ន្ធស្រោចស្រព ។ បន្តបង្កបរិយាកាស និងផ្តល់ការលើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យឯកជន ពិសេសការវិនិយោគក្នុងវិស័យកសិកម្ម ។

គ. បន្តជំរុញការអនុវត្តកំណែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបោសសម្អាតមីន ដោយផ្តោតសំខាន់លើការពង្រឹងប្រព័ន្ធគ្រប់គ្រង ការបែងចែកដីធ្លីប្រកបដោយសមធម៌ ការប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព ក្នុងនោះរួមទាំងដីសម្បទានសេដ្ឋកិច្ច ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការធានាសុវត្ថិភាពនៃកម្មសិទ្ធិដីធ្លី ឱ្យសមស្របតាមច្បាប់ភូមិបាល ដើម្បីជួយគាំទ្រដល់វិស័យកសិកម្ម សំដៅលើកកម្ពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម ដើម្បីឱ្យវិស័យនេះ ក្លាយទៅជាមូលដ្ឋានដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ច និងបម្រើឱ្យគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

ឃ. បន្តពង្រឹង និងពង្រីកប្រព័ន្ធធនាគារ វិស័យធានារ៉ាប់រង ទីផ្សារមូលបត្រ និងទីផ្សារភាគហ៊ុនក្នុងក្របខ័ណ្ឌនៃការបន្តជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីបង្កើនការកៀរគរធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងបង្កើនសក្តានុពលភាព និងកាលានុវត្តភាព ដល់ការធ្វើហិរញ្ញប្បទាន និងការអភិវឌ្ឍវិស័យឯកជន ។

ង. បន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ២ ជាពិសេស បន្តជំរុញការអនុវត្តផែនការសកម្មភាពជំហានទី ២ គឺ ***ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ*** ដោយផ្តោត

លើការរៀបចំ និងដាក់ឱ្យអនុវត្តនូវ ចំណាត់ថ្នាក់ថវិកាថ្មីបន្ថែមទៀត អង្គភាពថវិកា ស្តង់ដារគណនេយ្យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការសាកល្បងការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យា ។ ទន្ទឹមនឹងនេះ ***ការបន្តពង្រឹងភាពជឿទុកចិត្តលើថវិកា*** នៃជំហានទី ១ តាមរយៈការបន្តជំរុញការកែលម្អនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ដើម្បីធានាឱ្យការបើកផ្តល់ថវិកាបានទាន់ពេលវេលា ។ ការបន្តកសាង និងកែលម្អក្របខ័ណ្ឌគោលនយោបាយចំណូលរយៈពេលមធ្យមដើម្បីរក្សាស្ថិរភាព និងនិរន្តរភាពចំណូល ពិសេសផ្តោតការយកចិត្តទុកដាក់ លើការកសាង និងពង្រឹងការអនុវត្តក្របខ័ណ្ឌច្បាប់ យន្តការគ្រប់គ្រង និងប្រមូលពន្ធ និងអាករ ព្រមទាំងចំណូលមិនមែនសារពើពន្ធ រួមទាំងចំណូលពីធនធានធម្មជាតិផង ។ លើសពីនេះ ត្រូវបន្តជំរុញពង្រឹង និងបង្កើនការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី ដែលជាមូលដ្ឋានដ៏សំខាន់ និងចាំបាច់ក្នុងការ ***បង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ*** និងការ***បង្កើនគណនេយ្យភាពចំពោះសមិទ្ធកម្ម*** ដែលជាគោលដៅនៃជំហានទី ៣ និងទី ៤ ។

ឆ. បន្តជំរុញ **ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ** ពិសេស ការរៀបចំរចនាសម្ព័ន្ធរដ្ឋបាល ច្បាប់ និងលិខិតគតិយុត្តផ្សេងៗ ដើម្បីអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្នុងន័យនេះ **គណៈកម្មាធិការជាតិសម្រាប់ការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)** និង ក្រសួង- ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវសហការរៀបចំកម្មវិធីសកម្មភាពឱ្យបានច្បាស់លាស់ គ្រប់ជ្រុងជ្រោយ ជាជំហានៗ ប្រកបដោយភាពហ្មត់ចត់ និងប្រុងប្រយ័ត្នខ្ពស់ ដើម្បីធានាការអនុវត្តប្រកបដោយភាពរលូន និងប្រសិទ្ធភាព ។ ពិសេស ការពង្រឹងសមត្ថភាពរដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុរបស់គ្រប់ស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ ដើម្បីធានាការផ្ទេរអំណាច និងការទទួលខុសត្រូវពីថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាព ។

ជ. បន្តជំរុញការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការកែលម្អការគ្រប់គ្រងធនធានមនុស្ស ដើម្បីបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ ។ ក្នុងន័យនេះ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលត្រូវរៀបចំគោលនយោបាយរយៈពេលមធ្យម និងវែង សម្រាប់ការកែលម្អការគ្រប់គ្រងធនធានមនុស្សប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ជាពិសេសត្រូវបង្កើតយន្តការ និងបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យក្របខ័ណ្ឌមន្ត្រីរាជការ ការពង្រឹងការផ្តល់ទិដ្ឋាការឱ្យជ្រើសមន្ត្រីថ្មីបន្ថែមដោយផ្អែកលើការវិភាគលើតម្រូវការជាក់ស្តែង និងលទ្ធភាពថវិកាជាតិ ព្រមទាំងផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការចូលនិវត្តន៍ ។ ទន្ទឹមនឹងនេះ ត្រូវពិនិត្យពិចារណាឡើងវិញលើរាល់គោលនយោបាយ និងគោលការណ៍តម្លើង និងផ្តល់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ រួមទាំងការតម្លើងបៀវត្សមូលដ្ឋានប្រចាំឆ្នាំ ការតម្លើងកាំប្រាក់ ការអនុវត្តប្រាក់បំណាច់មុខងារ ការផ្តល់ប្រាក់ឧបត្ថម្ភផ្សេងៗ ដូចជា ប្រាក់ម៉ោង ប្រាក់យាម ប្រាក់បេសកកម្ម និងចំណាយប្រតិបត្តិការអាទិភាពជាដើម ដើម្បីធានាសមធម៌ តម្លាភាព សង្គតិភាព និងប្រសិទ្ធភាព ។

ឈ. បន្តជំរុញការអនុវត្តកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ពិសេស ការពង្រឹងសមត្ថភាពដឹកនាំ វិជ្ជាជីវៈជំនាញ សហប្រតិបត្តិការ និងការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ព្រមទាំងការកែសម្រួលរចនាសម្ព័ន្ធកងឯកភាពប្រយុទ្ធ និងការកាត់បន្ថយកងទ័ព ដើម្បីធានាការប្រើប្រាស់ និងគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ។

III. ការគណនា និង វិភាជន៍ថវិកាឆ្នាំ ២០១១

ក- គម្រោងចំណាយថវិកា

១៥- ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅទាំងអស់ខាងលើ និង ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈដែលបានគូសបញ្ជាក់ខាងលើ ថវិកាឆ្នាំ ២០១១ ត្រូវគ្រោងលើមូលដ្ឋានយុទ្ធសាស្ត្រ និងវិធានការដូចខាងក្រោម៖

- បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តសន្សំសំចៃលើមុខសញ្ញាចំណាយអគ្គិសនី ទូរស័ព្ទ និងប្រេងឥន្ធនៈ ដើម្បីរក្សាចំណាយសរុបឱ្យស្ថិតនៅក្នុងកម្រិត ១៨,១០% នៃផសស គឺកើនឡើងប្រមាណ ០,១៤% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ដែលក្នុងនោះចំណាយចរន្តសរុបនឹងត្រូវរក្សាឱ្យនៅត្រឹមប្រមាណ ១០,៩៥% នៃផសស និងចំណាយមូលធននឹងត្រូវរក្សានៅត្រឹមប្រមាណ ៧,១៥% នៃផសស ក្នុងទិសដៅរក្សាអតិរេកចរន្តក្នុងរង្វង់ ១,៦៨% នៃផសស និងឱនភាពថវិកាសរុបក្នុងរង្វង់ ៥,៣៧% នៃផសស ។ ដោយឡែក ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុកត្រូវកំណត់ក្នុងចំនួន ២,៨៩% នៃផសស ក្នុងនោះ ចំណាយសម្រាប់រំលស់បំណុលត្រូវកំណត់ត្រឹម ០,៣៣% នៃផសស ។ ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសត្រូវកំណត់ក្នុងចំនួន ៤,២៥% នៃផសស ។
- ត្រូវវិភាជន៍ចំណាយចរន្តទៅតាមវិស័យនីមួយៗ ដូចតទៅៈ វិស័យសង្គមកិច្ចស្មើនឹង ៤,០៤% នៃផសស មានកំណើន ០,១៨% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ វិស័យសេដ្ឋកិច្ច ០,៩០% នៃផសស មានកំណើន ០,០២% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ វិស័យរដ្ឋបាលទូទៅ ១,៤១% នៃផសស ថយចុះ ០,០៥% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ វិស័យការពារជាតិ និងសន្តិសុខ ២,៤១% នៃផសស ថយចុះប្រមាណ ០,០២% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។ ថវិកាផ្ទាល់របស់រាជធានី-ខេត្តសរុប មានប្រមាណ ០,៤៨% នៃផសស មានកំណើន ០,០៣% នៃផសស ឬ ១៤,៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

១៦- ទន្ទឹមនឹងនេះ ថវិកាឆ្នាំ ២០១១ ត្រូវបន្តបម្រើឱ្យគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច ព្រមទាំងការលើកស្ទួយជីវភាពប្រជាជននៅទីជនបទ សំដៅសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ថវិកាឆ្នាំ ២០១១ ត្រូវផ្តល់ការវិភាជជាក់ស្តែងទៅតាមគោលនយោបាយអាទិភាពរបស់វិស័យនីមួយៗ ដូចខាងក្រោម៖

- បន្តបង្កើនថវិកាសម្រាប់វិស័យអប់រំ និងសុខាភិបាលឱ្យស្របទៅតាមគោលដៅនៃកម្មវិធីចំណាយរយៈពេលមធ្យមសម្រាប់វិស័យអប់រំ និងសុខាភិបាលឆ្នាំ ២០១១-២០១៣ ។
- បន្តបង្កើនថវិកាសម្រាប់ការអភិវឌ្ឍប្រព័ន្ធស្រោចស្រព ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍកសិកម្ម និងការអភិវឌ្ឍជនបទ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញវិស័យសេដ្ឋកិច្ចដើម្បីកំណើន ការងារ សមធម៌ និង ការកាត់បន្ថយភាពក្រីក្រ ។
- មូលនិធិថវិកាឃុំ-សង្កាត់ឆ្នាំ ២០១១ ត្រូវកំណត់ស្មើនឹង ២,៩០% នៃចំណូលចរន្តថវិកាជាតិឆ្នាំ ២០១០ ដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

• ថវិកាខេត្ត ក្រុង ដែលរួមមានថវិកាផ្ទាល់ និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិ ហើយដែលនឹងត្រូវក្លាយទៅជាថវិកា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាពេលអនាគតដ៏ខ្លីខាងមុខ នៅពេលដែលរាល់ក្របខ័ណ្ឌគតិយុត្តសម្រាប់ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានដាក់ឱ្យអនុវត្ត ហើយរចនាសម្ព័ន្ធរដ្ឋបាល និងមុខងារត្រូវបានកំណត់ និងផ្ទេរចប់សព្វគ្រប់នោះ ត្រូវបន្តអនុវត្តតាមក្របខ័ណ្ឌច្បាប់ និងរាល់នីតិវិធីដែលមានជាធរមាន ស្របតាមមាត្រា ៨៧ នៃអន្តរប្បញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

• បន្តផ្តល់អាទិភាពនៃការវិភាជថវិកាដល់ថវិកាកម្មវិធី និង ផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាដែលបានបញ្ជាក់ពីទិសដៅគោលនយោបាយ គោលបំណង កម្មវិធី និង/ឬ យុទ្ធសាស្ត្រអាទិភាព ផែនការសកម្មភាព ព្រមទាំងលទ្ធផលរំពឹងទុក និងសូចនាករច្បាស់លាស់ ដើម្បីធានាការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងបង្កើនប្រសិទ្ធភាពថវិកា ជាពិសេស ការបន្តពង្រឹង និងការកែលម្អការរៀបចំ និងការអនុវត្តថវិកាកម្មវិធី ។

ខ- **គម្រោងចំណូលថវិកា**

១៧- ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃគម្រោងចំណាយខាងលើ ត្រូវបន្តពង្រឹងការគ្រប់គ្រងចំណូល និង ជំរុញការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ជាពិសេស ការកសាងគោលនយោបាយចំណូល និង ការអនុវត្តឱ្យបានសម្រេចទៅតាមផែនការសកម្មភាព និងគោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសម្រេចឱ្យបាននូវកម្រិតចំណូលក្នុងស្រុកសរុបប្រមាណ ១២,៧២% នៃផសស គឺមានកំណើន ០,១៦% នៃផសស ឬ ១០,៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ដែលក្នុងនោះ ចំណូលសារពើពន្ធត្រូវសម្រេចឱ្យបាន ១១,០៥% នៃផសស គឺមានកំណើន ០,៤៣% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឱ្យបាន ១,៥៧% នៃផសស គឺថយចុះ ០,២៦% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ និងចំណូលមូលធនក្នុងស្រុកត្រូវសម្រេចឱ្យបាន ០,១០% នៃផសស ប្រហាក់ប្រហែលនឹងឆ្នាំ ២០១០ ។

១៨- ដើម្បីសម្រេចបានតាមគោលដៅនៃការប្រមូលចំណូលសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ដែលបានកំណត់ខាងលើនេះ ត្រូវបន្តជំរុញឱ្យកាន់តែសកម្មថែមទៀតក្នុងការអនុវត្តសកម្មភាពការងារ និងបណ្តាវិធានការទាំងឡាយនៅក្នុងកម្មវិធីសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ត្រូវផ្តោតលើបណ្តាវិធានការសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

ទី១- ផ្នែកចំណូលពន្ធដារ:

- បន្តពង្រឹង និងកែលម្អរដ្ឋបាលពន្ធដារ ពង្រឹងការងារសវនកម្មពន្ធ ពិនិត្យលទ្ធភាពពង្រីកមូលដ្ឋានយកពន្ធ បង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ និងការធ្វើវិចារណកម្មប្រព័ន្ធលើកទឹកចិត្ត ។

- បន្តពង្រឹងការអនុវត្តកម្មវិធីកែលម្អរចនាសម្ព័ន្ធ ជាពិសេស ការពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងប្រតិបត្តិការរបស់អគ្គនាយកដ្ឋានពន្ធដារ ស្របតាមប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ ។

- បន្តបញ្ចប់ការកសាង និងចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និងការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។

- បន្តពង្រឹងការអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយ និងឱ្យបានម៉ឺងម៉ាត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និងវិសោធនកម្មទាំងឡាយនៃច្បាប់នេះ ។

- បន្តអនុវត្តគោលនយោបាយពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីក និងពង្រឹងការអនុវត្តរបបពិតនៅតាមបណ្តារាជធានី- ខេត្ត និងបន្តពង្រឹងសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ ។

- បន្តបណ្តុះបណ្តាល និងបង្កើនសមត្ថភាពវិជ្ជាជីវៈ និងសីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងរដ្ឋបាលពន្ធដារឱ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឱ្យបានល្អនូវអ្នកបង់ពន្ធធំ និងមធ្យម ។

- បន្តពង្រឹងលិខិតបទដ្ឋានស្តីពីពន្ធក្នុងវិស័យប្រេង និងឧស្ម័ន ដើម្បីធានាឱ្យបាននូវការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាពពីវិស័យនេះ ជាពិសេស ការបន្តពិនិត្យពិចារណាលើការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) ដើម្បីរៀបចំបញ្ចូលពន្ធលើប្រេង និងឧស្ម័ន ។

- បន្តធ្វើការសិក្សាអំពីវិចារណកម្មបន្ត និងលទ្ធភាពវិសោធនកម្មបន្តលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និងបណ្តាច្បាប់ពាក់ព័ន្ធ ក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ ។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ ។

ទី២- ផ្នែកចំណូលពន្ធគយ:

- បន្តជំរុញការរៀបចំតាមការចាំបាច់នៃការងារនូវលិខិតបទដ្ឋាននានា ដើម្បីជំរុញការអនុវត្តច្បាប់គយ ពិសេសសម្រាប់បន្តកែលម្អបរិស្ថានធុរកិច្ច និងវិនិយោគ និងសម្រាប់រឹតបន្តឹងវិធានការបំបាត់អំពើរត់ពន្ធគយ ។

- បន្តកែលម្អនីតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ- ចូល ដោយតម្រូវឱ្យមានការរៀបចំជាក្រុម-ហ៊ុននាំចេញ- ចូល និងក្រុមហ៊ុនដើងសារច្បាស់លាស់ ដើម្បីធានានូវតម្លាភាព និងភាពងាយស្រួល ក្នុងការត្រួតពិនិត្យ និងក្នុងការយកពន្ធ និងអាករផ្សេងៗ ។

- បន្តរៀបចំកែលម្អនិងដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

- បន្តជំរុញការអនុវត្តវិធានការតឹងរឹងក្នុងការបង្កើនចំណូលពន្ធគយរួមមាន៖

ក. បន្តពង្រឹងការអនុវត្តបណ្តាវិធានការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាល អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរដែនដី ។ គណៈកម្មាធិការបង្ក្រាបអំពើរត់ពន្ធ ត្រូវបន្តពង្រឹងការអនុវត្តការងាររបស់ខ្លួនឱ្យកាន់តែខ្លាំងក្លា និងប្រកបដោយប្រសិទ្ធភាពថែមទៀត ក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ ។ ក្នុងការអនុវត្តភារកិច្ចនេះ ត្រូវយកចិត្តទុកដាក់ ជាពិសេស លើវិធានការកែលម្អផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធដោយផ្តោតលើមុខទំនិញមួយចំនួនដែលមានវេយិទភាព ដូចជា ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូន បរិក្ខារអេឡិចត្រូនិច និងការដាក់ចេញនូវនីតិវិធីត្រួតពិនិត្យថ្មី ។

ខ. បន្តពង្រឹងការសហការជាមួយអគ្គនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និងផ្លាស់ប្តូរព័ត៌មាន រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្តីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និងកាតព្វកិច្ចពន្ធដារ ។

គ. បន្តរិះរក និងដាក់ឱ្យអនុវត្តនូវវិធានការច្បាស់លាស់ និងទន់ភ្លន់ លើមុខទំនិញមួយចំនួន ដើម្បីរក្សាប្រភពចំណូល ។

- បន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការពង្រឹងស្ថាប័នគយ និងរដ្ឋាករមានជាអាទិ៍ៈ បន្តការបណ្តុះ-បណ្តាល និងការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និងសីលធម៌របស់មន្ត្រីគយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងរដ្ឋបាលគយ ឱ្យបានរឹងមាំ ។

- បន្តពង្រឹង និងពង្រីកការអនុវត្តស្វ័យប្រវត្តិកម្មនីតិវិធីគយ និងយន្តការគ្រប់គ្រងហានិភ័យ ដើម្បីកែលម្អប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និងលើកកំពស់គុណភាពសេវាកម្ម ជូនដល់អតិថិជន ។

- បន្តពង្រឹងយន្តការអធិការកិច្ចមុនពេលផ្ទុក ការត្រួតពិនិត្យទំនិញ ការត្រួតពិនិត្យនាវាឆ្លងកាត់ ការបញ្ជូនទំនិញ ការធ្វើអធិការកិច្ចនៅនឹងកន្លែង និងការប្រមូលចំណូល ។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

ទី៣- ផ្នែកចំណូលមិនមែនសារពើពន្ធ:

- បន្តជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

- បន្តជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ពិសេស បទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។ ពិសេស បន្តពង្រឹងការប្រមូលចំណូលពីកិច្ចសន្យាសម្បទានគ្រប់ប្រភេទ ដើម្បីធានាឱ្យមានការបង់ចំណូលទាំងនេះចូលថវិការដ្ឋឱ្យបានទៀងទាត់ទាន់ពេលវេលា និងដោយគ្មានការកាត់ទុកសម្រាប់ចំណាយដោយប្រការណាមួយឡើយ ។

- បន្តស្រាវជ្រាវ និងកំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ហើយបន្តជំរុញការអនុវត្តនូវផែនការសកម្មភាព និងបណ្តាវិធានការ ដើម្បីតឹងទារបំណុលទាំងអស់នេះ តាមគ្រប់មុខសញ្ញាទាំងអស់ ។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ អាកាសចរស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និងចំណូលពីការជួលរោងចក្រសហគ្រាស និងទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។

- បន្តជំរុញដើម្បីបញ្ចប់ការងារធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ហើយចាប់ផ្តើមធ្វើបញ្ជីសារពើភ័ណ្ឌដីរបស់រដ្ឋជាបណ្តើរៗ ដើម្បីពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការប្រមូលចំណូល ។

- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសម្បទាន និងពង្រឹងកិច្ចដំណើការផ្តល់ និងគ្រប់គ្រងកិច្ចសន្យាសម្បទានគ្រប់ប្រភេទទាំងអស់ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីកិច្ចសន្យាសម្បទានគ្រប់ប្រភេទចូលថវិកាជាតិ ។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និងទូរគមនាគមន៍ តាមរយៈការពង្រឹងយន្តការតើងទារចំណូល ដោយតម្រូវឱ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់បង់ចំណូលដោយត្រង់ទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅធនាគារជាតិ ហើយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការបង់ចំណូលនេះ ។

១៩- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ នេះ គឺជាឧបករណ៍ដ៏សំខាន់បំផុតសម្រាប់ឈានទៅសម្រេចឱ្យបាននូវបណ្តាគោលដៅជាអាទិភាពខាងលើ ។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលមានភាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលានូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចាប់ផ្តើមការចរចា និង ពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ជាមួយក្រសួង- ស្ថាប័ន និងមន្ទីរជំនាញរាជធានី- ខេត្ត ទាំងអស់ចាប់ពីថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១០ រហូតដល់ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១០ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយធ្វើជូនគណៈរដ្ឋមន្ត្រីឱ្យបាននៅក្នុងសប្តាហ៍ទី ១ នៃ ខែតុលា ឆ្នាំ ២០១០ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយធ្វើជូនរដ្ឋសភាឱ្យបានក្នុងសប្តាហ៍ទី ១ នៃខែ វិច្ឆិកា ឆ្នាំ ២០១០ ដើម្បីស្ថាប័ននីតិបញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យ ពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះឱ្យបានមុនថ្ងៃ ២៥ ខែ ធ្នូ ២០១០ ។

គ- បញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១

២០- ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានធ្វើឱ្យប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំនូវការគ្រប់គ្រងចំណូល និងចំណាយ ពិសេស រាជរដ្ឋាភិបាលបានដោះស្រាយបំណុលចាស់ទាំងស្រុង និងបានបញ្ឈប់ប្រពៃណីខ្វះសាច់ប្រាក់ទូទាត់ចំណាយផងដែរ ។ ទោះជាយ៉ាងនេះក៏ដោយ យើងនៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តជំរុញ ជាពិសេស ភាពចាំបាច់ក្នុងការបង្កើនចំណូលពន្ធដារក្នុងស្រុកដើម្បីបំពេញនិន្នាការថយចុះនៃចំណូលពន្ធនាំចូល និងតម្រូវការចំណាយដែលចេះតែកើនឡើងជាលំដាប់ ដែលរួមមានដូចជាៈ

ទី១- ការបន្តជំរុញការយកចិត្តទុកដាក់លើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឱ្យបានសមស្របដើម្បីធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ហើយពង្រឹងការរៀបចំថវិកាឱ្យបានគ្រប់ជ្រុងជ្រោយ និងសុក្រិត ដើម្បីកាត់បន្ថយជាអតិបរមានូវចំណាយមិនបានគ្រោងទុក និងសំដៅបំបាត់ចំណាយក្រៅគម្រោងថវិកា និងចំណាយដែលមិនចាំបាច់ ដើម្បីសម្រេចបាននូវការគ្រប់គ្រងថវិកាជាតិប្រកបដោយភាពជឿទុកចិត្តបាន គណនេយ្យភាព និងប្រសិទ្ធភាព ។

ទី២- ការបន្តជំរុញការរៀបចំកម្មវិធីចំណូល- ចំណាយឱ្យបានសុក្រិត និងការអនុវត្តឱ្យបានម៉ឺងម៉ាត់ដើម្បីជាមូលដ្ឋានក្នុងការកសាងផែនការសាច់ប្រាក់ សំដៅពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ធានាបង្កើនភាពជឿទុកចិត្តបាន និងគណនេយ្យភាពលើការអនុវត្តថវិកា ។ លើសពីនេះ ការបង្កើនការគោរពយ៉ាងម៉ឺងម៉ាត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ពិសេសវិន័យថវិកាទាំង ១០ ។

ទី៣- បន្តពង្រឹងការគ្រប់គ្រងបំណុល ពិសេស ការកសាងទិន្នន័យ និងការរៀបចំកម្មវិធីសងបំណុលឱ្យបានច្បាស់លាស់ និងដោយផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌនៃការរៀបចំថវិកា និងការបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវការខ្ចីតែឥណទានសម្បទាន និងដែលបម្រើឱ្យគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ។

ទី៤- បន្តបង្កើនចំណាយលើវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច ជាពិសេស ចំពោះគោលនយោបាយអាទិភាព ដូចជា អប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍន៍ជនបទ និង ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មានផ្លូវថ្នល់ ស្ពាន និងប្រព័ន្ធស្រោចស្រព ដែលជាគោលបំណងនៃគោលនយោបាយ និងជាទិសដៅយុទ្ធសាស្ត្រអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

ទី៥- ការប្រឈមនឹងស្ថានភាពវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោក ដែលនៅពុំទាន់ប្រាកដថាបានឆ្លងផុតនៅឡើយទេ ពិសេស ឥទ្ធិពលអវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជា និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាការអនុវត្តថវិកាដែលអាចនឹងនៅបន្ត តាមរយៈការបន្តធ្លាក់ចុះ ឬ មិនទាន់ងើបឡើងវិញនៃតម្រូវការពិភពលោក អត្រានៃការអត់ការងារធ្វើនៅមានកម្រិតខ្ពស់ ការប្រែប្រួល និងភាពមិនប្រក្រតីនៃថ្លៃប្រេងឥន្ធនៈ និងតម្លៃរូបិយប័ណ្ណអាមេរិកធៀបនឹងរូបិយប័ណ្ណនៃប្រទេសជាដៃគូពាណិជ្ជកម្មកម្ពុជា ជាដើម ។

IV- នីតិវិធី និង បច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០១១

ក- ការគ្រោងចំណូលថវិកាឆ្នាំ ២០១១

២១- ការគ្រោងគិតចំណូលចរន្តរបស់ថវិកា អាស្រ័យលើប្រភពធនធាននៃផលិតផល ឬ ផលទុនដែលជាប្រភពចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងបណ្តាលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ÷

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
  - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  - ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ចនៅពេលខាងមុខ
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រា និងមូលដ្ឋានប្រមូលពន្ធ
  - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបាន ដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយ និងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ ។
- ចំពោះចំណូលពុំមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជា កិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹង និងកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម ។ល។

ខ- ការគ្រោងចំណាយថវិកាឆ្នាំ ២០១១

២២- ការរៀបចំគម្រោងគណនាទានចំណាយថវិកា ត្រូវផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា ដែលបានផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគណនាតម្រូវការថវិកាដោយលំអិតទៅតាមជំពូក គណនី និង អនុគណនី និងទៅតាមនាយកដ្ឋាន និងអង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះឱ្យក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត (តាមគំរូដែលភ្ជាប់មកជាមួយស្រាប់) ដោយផ្អែកលើតម្រូវការជាក់ស្តែង និង ដោយផ្ទាល់ សម្រាប់បម្រើឱ្យការអនុវត្តកម្មវិធីសកម្មភាពចាំបាច់ ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ រីឯការគណនាគណនាទានចំណាយ ត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា តារាងបុគ្គលិក បញ្ជីប៉ាន់ស្មានតម្លៃសម្ភារៈនៃការផ្គត់ផ្គង់ និងត្រូវផ្អែកទៅតាមធម្មនិយាមចំណាយ ដែលបានកំណត់នៅក្នុងប្រកាស ឬ សេចក្តីណែនាំ ដូចជា ចំណាយបេសកកម្ម ចំណាយមធ្យមភាគលើគ្រែមួយរបស់អ្នកជំងឺនៅមន្ទីរពេទ្យ ចំណាយខាងការសិក្សាសម្រាប់សិស្ស ឬ និស្សិតម្នាក់ ឬ ត្រូវផ្អែកទៅតាមតួលេខស្ថិតិជាមធ្យមភាគរបស់គណនេយ្យថវិកាសម្រាប់ការគ្រប់គ្រងកន្លងមក ។ ជាពិសេស តម្រូវការចំណាយនីមួយៗ ត្រូវមានការវិភាគយ៉ាងល្អិតល្អន់ និងមានឯកសារគាំទ្រភ្ជាប់មកជាមួយ ដើម្បីពន្យល់ទៅតាម ជំពូក គណនី និង អនុគណនីនីមួយៗ ។

គ- ការកំណត់កញ្ចប់ថវិកាឆ្នាំ ២០១១

២៣- រាជរដ្ឋាភិបាលបានផ្ញើការកំណត់នូវកញ្ចប់ថវិកា ដោយកំណត់គោលការចំណាយទៅតាមប្រភេទ និងជំពូក ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកា សម្រាប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ធ្វើជាមូលដ្ឋានក្នុងការរៀបចំគម្រោងចំណាយលំអិតទៅតាមគណនី និងអនុគណនី និងទៅតាមនាយកដ្ឋាន និងអង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះឱ្យក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដើម្បីបម្រើឱ្យតម្រូវការជាក់ស្តែងក្នុងការអនុវត្តកម្មវិធីសកម្មភាពចាំបាច់ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ ដូចជាឆ្នាំមុនៗដែរ ក្នុងរយៈពេលអនុវត្តថវិកានៃឆមាសទី ១ ឆ្នាំ ២០១១ នេះ នឹងមិនមានការអនុញ្ញាតឱ្យធ្វើនិយ័តភាពផ្ទៃក្នុងថវិការបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ទេ ។

២៤- ក្រសួង-ស្ថាប័ននិងមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវគ្រោងចំណាយទៅតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និងបណ្តាវិធានការដូចខាងក្រោម៖

ក- ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤) ត្រូវគ្រោងដោយបង្កើន ២០% លើប្រាក់បៀវត្សមូលដ្ឋាន ទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សថ្មីនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០១០ ។ ចំពោះចំនួនមន្ត្រីរាជការបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងដែលមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬ លាឈប់ពីក្របខ័ណ្ឌរដ្ឋ និង មរណភាព ត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន ។ ប្រសិនបើមានការតម្លើងឋានៈ ឬ មានមន្ត្រីថ្មី ត្រូវគ្រោងដោយឡែក ។ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត មិនត្រូវគិតអតិផរណានៅក្នុងចំណាយបៀវត្សនេះទេ ។ ចំពោះ បុគ្គលិកអណ្តែត និងភ្នាក់ងារជាតិជាប់កិច្ចសន្យា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវ

ស្នើសុំការធានាចំណាយថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឱ្យក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី- ខេត្ត ជ្រើសរើស និងប្រើប្រាស់ ។

ខ- ចំណាយសម្រាប់ការទិញ និងសេវា មួយចំនួនត្រូវគ្រោងប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃបំផុត ពិសេសចំពោះសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ និងការទទួលភ្ញៀវ មិនត្រូវបង្កើនចំណាយលើសពីឆ្នាំកំពុងអនុវត្តទេ ។ នៅពេលអនុវត្តថវិកា ហាមដាច់ខាតមិនឱ្យមានចំណាយលើសពីឥណទានថវិកាដែលបានគ្រោងសម្រាប់មុខសញ្ញានេះ និងហាមដាច់ខាតមិនឱ្យមានការជំពាក់បំណុលដោយខ្ចីទំនិញ ឬសេវាមកប្រើប្រាស់នៅក្រៅហិរិបថវិកាឡើយ ។ កន្លងមកចំណាយសម្រាប់មុខសញ្ញាអគ្គិសនី ទូរស័ព្ទ ទឹក ប្រេងឥន្ធនៈ និងការទទួលភ្ញៀវ មានលក្ខណៈខ្ជះខ្ជាយ ។ ចំណាយសម្រាប់មុខសញ្ញាទាំងនេះ ចេះតែកើនឡើងហើយការទូទាត់មិនបានទាន់ពេលវេលាដែលនាំឱ្យមានបំណុលកកស្ទះពីមួយឆ្នាំទៅមួយឆ្នាំ ។ ដើម្បីដោះស្រាយបញ្ហានេះ ចំពោះចំណាយ អគ្គិសនី ទូរស័ព្ទ និង ទឹកត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង- ស្ថាប័នទាំងអស់ ត្រូវសហការត្រួតពិនិត្យលើការប្រើប្រាស់បច្ចុប្បន្ន ដើម្បីរៀបចំយន្តការ និងប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និងទឹក ឱ្យបានត្រឹមត្រូវ ម៉ត់ចត់ និងប្រកបដោយប្រសិទ្ធភាព ។ ក្នុងករណីរកឃើញការលួចបន្តចរន្តអគ្គិសនី ទូរស័ព្ទ និងទឹកប្រើប្រាស់ផ្ទាល់ខ្លួនខុសមុខសញ្ញារបស់ក្រសួង- ស្ថាប័នណាមួយ រដ្ឋមន្ត្រីក្រសួងនោះ គឺជាអ្នកទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និងចំពោះមុខរដ្ឋសភា ។ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និងក្រុមហ៊ុនទូរស័ព្ទត្រូវកាត់ផ្តាច់បណ្តាញលួចលាក់ទាំងនោះភ្លាម ហើយធ្វើរបាយការណ៍ជូនក្រសួងអាណាព្យាបាលបច្ចេកទេស និង ក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ និងចម្លងជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង- ស្ថាប័នទាំងអស់ ត្រូវសហការគ្រោងឥណទានសម្រាប់អគ្គិសនី ទូរស័ព្ទ និងទឹក ប្រកបដោយភាពសន្សំសំចៃខ្ពស់ ដោយយកចំណាយជាក់ស្តែងពីឆ្នាំមុន ធ្វើជាពិតាន ហើយកាត់បន្ថយចំណាយមុខសញ្ញានេះឱ្យចុះមកនៅក្នុងកម្រិតមួយសមស្រប តាមការចាំបាច់ ពិតប្រាកដរបស់ក្រសួង- ស្ថាប័ន ។

- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និងក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទ ត្រូវផ្តល់វិក្កយបត្រប្រចាំខែនីមួយៗ ឱ្យបានមុនថ្ងៃទី ១៥ នៃខែ បន្ទាប់ ។ ក្រសួង- ស្ថាប័ន និងមន្ទីរជំនាញរាជធានី- ខេត្តទាំងអស់ត្រូវធ្វើការផ្ទៀងផ្ទាត់វិក្កយបត្រ និងរៀបចំទូទាត់ឱ្យបានទៀងទាត់ និងទាន់ពេលវេលារៀងរាល់ខែ ។ ហាមដាច់ខាតមិនឱ្យមានការពន្យារការទូទាត់លើមុខសញ្ញាចំណាយនេះ ដោយយកឥណទាននេះទៅប្រើប្រាស់លើមុខសញ្ញាផ្សេង ហើយផ្ទេរបន្ទុកនេះមកលើថវិការួមទេ ។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវស្នើឡើងនូវវិធានការជាក់លាក់ ក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និងទឹក ដើម្បីដាក់ជូនប្រមុខនៃរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ហើយដាក់ឱ្យគ្រប់ក្រសួង- ស្ថាប័នរបស់រាជរដ្ឋាភិបាលអនុវត្តឱ្យបានខ្ជាប់ខ្ជួន និងម៉ឺងម៉ាត់បំផុត ។

គ- ចំពោះចំណាយសម្រាប់ជំពូក គណនី និង អនុគណនីផ្សេងៗទៀត ត្រូវគ្រោងទៅតាមតម្រូវការចាំបាច់ដោយផ្អែកលើមូលដ្ឋានផែនការសកម្មភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ក្នុងករណី

តម្រូវឱ្យមានកំណើន ដោយមានការវិភាគ និងពន្យល់ច្បាស់លាស់ ក៏កំណើននោះមិនត្រូវឱ្យលើសពី ៣% នៃកញ្ចប់ថវិកាដែលបានអនុម័តឆ្នាំ ២០១០ ដែរ ។ ចំពោះក្រសួង-ស្ថាប័នដែលត្រូវបន្ត ឬ ចាប់ផ្តើមអនុវត្ត សាកល្បងថវិកាកម្មវិធី ត្រូវញែកគម្រោងចំណាយជាពីរផ្នែកសម្រាប់ថវិកាកម្មវិធី និងថវិកាមិនមែនកម្មវិធី ទៅតាមគ្រប់ ជំពូក គណនី និងអនុគណនីនីមួយៗ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវអញ្ជើញក្រសួងទាំងនេះ មកការពារគម្រោងថវិកាកម្មវិធីដោយឡែក ។

ឃ- ឯកសារផែនការយុទ្ធសាស្ត្រថវិកា គម្រោងចំណូល និងគម្រោងចំណាយថវិកា ដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាមូលដ្ឋានសម្រាប់ការពិភាក្សា នៅក្នុងកិច្ចប្រជុំការពារថវិកា ដើម្បីការពារកញ្ចប់ថវិការបស់ខ្លួន ។ ដូច្នេះ ក្នុងករណីដែលក្រសួង-ស្ថាប័ន ឬ មន្ទីរជំនាញរាជធានី-ខេត្ត ដែលមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់ការប្រជុំការពារថវិកាទេ នោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅអង្គភាពឱ្យបានទាន់ពេលវេលា ដើម្បីបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការ យកមូលដ្ឋាននៃថវិកាឆ្នាំ ២០១០ ហើយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូក គណនី និងអនុគណនីខាងលើ សម្រាប់កំណត់គម្រោងថវិការបស់អង្គភាពនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការប្រជុំការពារថវិកា និង រៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលា ។

ឃ-ការរៀបចំ និង ការវិភាគសំណើនានា

២៥- ថវិកាកំពុងប្រព្រឹត្តទៅឆ្នាំ (ក-1) ឆ្នាំ ២០១០ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៩/០២៦ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ត្រូវធ្វើជាមូលដ្ឋាននៃការរៀបចំថវិកាឆ្នាំ ២០១១ ឆ្នាំ (ក) ដើម្បីធានាឱ្យសេវាសាធារណៈនានាអាចដំណើរការទៅបាន ។ ក្រសួង-ស្ថាប័ន ត្រូវតែផ្អែកលើថវិកានៃឆ្នាំកំពុងប្រព្រឹត្តទៅ និងការណែនាំទាំងឡាយខាងលើនេះ សម្រាប់ធ្វើជាមូលដ្ឋាន ដោយគ្រាន់តែសម្រួលទៅតាមតម្រូវការចាំបាច់ដែលទាក់ទងទៅនឹងបណ្តាមូលហេតុ ដូចខាងក្រោម÷

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងប្រព្រឹត្តដូចជា៖
  - ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង-ស្ថាប័ន ព្រមទាំងមន្ទីរជំនាញរាជធានី-ខេត្តមានការប្រែប្រួល ។
  - ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ។
- ផលប៉ះពាល់ជាយថាហេតុនៃអតិផរណានៅក្នុងឆ្នាំទៅលើថ្លៃនៃផលិតផលចាំបាច់ ដូចជា អគ្គិសនី ទឹក ប្រេងឥន្ធនៈ សោហ៊ុយដឹកជញ្ជូន និងចំណាយរដ្ឋបាល ។ ល ។

២៦- គម្រោងថវិការបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវតែបញ្ជាក់នូវមូលហេតុច្បាស់លាស់ ដូចមានចែងខាងលើនេះ ហើយរាល់សំណើបន្ថែមត្រូវតែមានការពន្យល់បញ្ជាក់ភ្ជាប់មកជាមួយ នូវរាល់កង្វះខាតឥណទានថវិកានៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ដែលអាចយកមកពិភាក្សាបានលុះត្រាតែមានទៅ ក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពនៃឆ្នាំផែនការ ។

២៧- ឥណទានថវិកាដែលបានគិតគូរដោយផ្អែកលើមូលដ្ឋានខាងលើនេះ នឹងមានការប្រែប្រួល អាស្រ័យដោយមានការពង្រីកសកម្មភាពនៃឆ្នាំកំពុងប្រព្រឹត្តទៅ ឬ មានកម្មវិធីសកម្មភាពថ្មី ដែលត្រូវចាប់ផ្តើម អនុវត្តនៅក្នុងឆ្នាំនៃផែនការ ។

២៨- បច្ចេកទេសវិភាគដ៏ទៃទៀត គឺយកចំណាយថវិកាឆ្នាំមុន ដូចជា ចំណាយដំណើរការរដ្ឋបាល សម្រាប់មន្ត្រីរាជការម្នាក់ៗ ទ្រង់ទ្រាយនៃចំណាយ ប្រភពនៃចំណាយ និងអត្ថប្រយោជន៍នៃចំណាយចាំបាច់ មួយចំនួន សម្រាប់ធ្វើជាមូលដ្ឋានគ្រោងគិតសម្រាប់ឆ្នាំផែនការ ។ ជាពិសេស ឥណទានថវិកាចាំបាច់របស់ ក្រសួង- ស្ថាប័ន និងមន្ទីរជំនាញរាជធានី- ខេត្តនីមួយៗ ត្រូវតែបម្រើទៅលើ÷

- ទិសដៅ និងគោលបំណងនៃគោលនយោបាយរបស់ក្រសួង- ស្ថាប័ន និងមន្ទីរជំនាញរាជធានី- ខេត្តនីមួយៗ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា
- កម្មវិធី និងយុទ្ធសាស្ត្រអាទិភាពដែលបានកំណត់ច្បាស់លាស់ ដើម្បីសម្រេចបាននូវគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន
- ផែនការសកម្មភាព និងវាល់មធ្យោបាយដំណើរការ ដើម្បីអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព
- ការគ្រប់គ្រង ការតាមដាន ការវាយតម្លៃ និងការធ្វើរបាយការណ៍ដើម្បីបង្ហាញពីលទ្ធផលនៃការ អនុវត្តកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព ដែលជាមូលដ្ឋានសម្រាប់សម្រេចបានគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន ។

V- សេចក្តីសន្និដ្ឋាន

២៩- ខ្លឹមសារនៃសារាចរណែនាំនេះ បានផ្តល់នូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ព្រមទាំងគោលការណ៍ និងនីតិវិធីក្នុងការគ្រោងចំណូល និងចំណាយចាំបាច់សម្រាប់ជា មូលដ្ឋាន ដល់ក្រសួង- ស្ថាប័ន និងមន្ទីរជំនាញរាជធានី- ខេត្ត ដើម្បីរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ របស់ខ្លួនឱ្យឆ្លើយតបទៅនឹងកម្មវិធី យុទ្ធសាស្ត្រអាទិភាព ព្រមទាំងទិសដៅ និងគោលបំណងនៃគោល- នយោបាយតាមវិស័យ និងតាមផ្នែករៀងៗខ្លួន សំដៅបម្រើឱ្យបានសម្រេចនូវគោលដៅ **ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម** ក៏ដូចជាគោលដៅនៃ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** របស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យគឺ ការរក្សាកំណើន ប្រកបដោយចីរភាពក្នុងរង្វង់ប្រមាណ ៧% និងការកាត់បន្ថយភាពក្រីក្រឱ្យបានជាង ១% ក្នុងមួយឆ្នាំៗ ព្រមទាំងការបន្តរក្សា ឱ្យបាននូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគន្លឹះ និងចាំបាច់បំផុត ក្នុងការឈានទៅ សម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ ***ភាពសុខដុមរមនាសង្គម និង សុខុមាលភាពរបស់ប្រជាជន*** ។ ដូច្នេះ ដើម្បីឱ្យធនធាននេះអាចប្រើប្រាស់ប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់នោះ ទាមទារឱ្យគ្រប់ក្រសួង- ស្ថាប័នទាំងអស់មានទិសដៅ និងគោលបំណងនៃ គោលនយោបាយរបស់ខ្លួនយ៉ាងច្បាស់លាស់ដែលផ្សារភ្ជាប់ទៅនឹង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម** មានកម្មវិធី និងយុទ្ធសាស្ត្រអាទិភាពជាក់លាក់ ព្រមទាំងផែនការសកម្មភាពត្រឹមត្រូវ ក្នុងការ អនុវត្តឆ្ពោះទៅសម្រេចឱ្យបាននូវគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន ។ ទន្ទឹមនឹងនេះ

រាជរដ្ឋាភិបាលនឹងបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អ តាមរយៈកម្មវិធីកែទម្រង់ស៊ីជម្រៅលើ គ្រប់វិស័យ ជាពិសេស ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ និងការប្រយុទ្ធប្រឆាំងនឹង អំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ។

៣០- ពេលទទួលសារាចរណែនាំនេះ ***គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល-ចំណាយថវិការបស់ខ្លួន សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ជំនួសពីរច្បាប់ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០ ១០*** ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាកម្រិតជំនាញ និងបូកសរុបសម្រាប់ការចរចាចាប់ពីថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១០ រហូតដល់ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១០ ។ តួលេខគម្រោង ចំណូល-ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3...) ហើយឯកតាទាបបំផុតគិតត្រឹម 0,1 លាន រៀល ។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត មានចំណុច ណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ។

ធ្វើនៅភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា

"ដើម្បីជូនជ្រាប"

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អភិបាលរាជធានី-ខេត្ត
- គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៤២៧ ឧរថ.កស.ប/២៨

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែឧសភាឆ្នាំ២០១០

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ៥១៣ /១០ គ.វ.ក ចុះថ្ងៃទី១២.០៣.២០១០ របស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ខេ.អេ.អិម ហ្គាមេន ចុះថ្ងៃទី០៥.០៣.២០១០

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន ខេ.អេ.អិម ហ្គាមេន តំណាងដោយ លោក CHEN, JU-CHIN សញ្ជាតិចិន(តៃវ៉ាន់) អាយុ៥៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 200224363 ចុះថ្ងៃទី២៨.១២.២០០២ មានអាសយដ្ឋានបច្ចុប្បន្ន៖ #633 Phueng Khueng, S/K Pueng Fong, Sin Chou District, Taiwan. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

-ឈ្មោះផលិតផល	លេខចុះបញ្ជីផលិតផល ISIC Code
សម្លៀកបំពាក់	៣២២០

-ផ្លាកឈ្មោះរោងចក្រ ៖ *"ខេ.អេ.អិម ហ្គាមេន (K.A.M GARMENT CO., LTD.)"* ./.

-ទីតាំងរោងចក្រ ៖ *"ក្រុមទី២០ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ"*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៩៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាម បទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមាន ប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន:

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៤២៣៧ ឧ.ដ.ក.ឧ - ប្រក -

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ២៧១២ /០៩ គ.វ.ក ចុះថ្ងៃទី១៧.១២.២០០៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ស៊ីន យី ចាង អ៊ិនធើណាស្សូណាល់ ចុះថ្ងៃទី១៨.០៥.២០១០

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន ស៊ីន យី ចាង អ៊ិនធើណាស្សូណាល់ តំណាងដោយ លោក CHENG, WEI-CHING សញ្ជាតិចិន(តៃវ៉ាន់) អាយុ៥៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 213022526 ចុះថ្ងៃទី ០៨.០៨.២០០៥ មានអាសយដ្ឋានបច្ចុប្បន្ន៖ No 638, Chang-Ching Road, Yu-Ho City, Taipez,Taiwan, R.O.C ជាម្ចាស់ រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

-ឈ្មោះផលិតផល	លេខចុះបញ្ជីផលិតផល ISIC Code
សម្លៀកបំពាក់	៣២២០

-ផ្លាកឈ្មោះរោងចក្រ ៖"ស៊ីន យី ចាង អ៊ិនធើណាស្យូណាល់ (SIN YI CHANG INTERNATIONAL CO., LTD.)"

-ទីតាំងរោងចក្រ ៖ *"ផ្លូវជាតិលេខ៤ ភូមិត្រពាំងគល់ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល"*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានចំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចដូល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសបញ្ញត្តិ តាមមាត្រា៥៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចែកចាយលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាម បទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការ ចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមាន ប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬ ករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: -ប្រកាសលេខ១២៨៦ ឧរថ.កឧ.ប្រក និង វិញ្ញាបនប័ត្របង្កើតរោងចក្រ លេខ ១១០ ឧរថ.កឧ.បរ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលមានទីតាំង ផ្លូវជាតិលេខ៤ ភូមិអង្គកែវ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៥: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

ប្រការ១៦: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន:
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -រាជកិច្ច
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងពាណិជ្ជកម្ម
- -សាលាខេត្តកណ្តាល
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ: [illegible] ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ ១៩៧៦ /០៩ ក.អ.ក ចុះថ្ងៃទី០១.០៩.២០០៩ របស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន វីណាកូមិន្ទ ឫទ្ធី ខមភេនី អិលធីឌី ចុះថ្ងៃទី២៨.០៧.២០០៩

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន វីណាកូមិន្ទ ឫទ្ធី ខមភេនី អិលធីឌី តំណាងដោយ លោក DO HUY HOANG សញ្ជាតិវៀតណាម អាយុ៣៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ B1490740 ចុះថ្ងៃទី ១៨.០៩.២០០៧ មានអាសយដ្ឋានបច្ចុប្បន្នៈ Flat 12(206) - Block B1 - Khuong Thuong, Dong Da District, Ha Noi, Vietnam ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

-ឈ្មោះផលិតផល	លេខចុះបញ្ជីផលិតផល ISIC Code
ឥដ្ឋ-គ្រឿងអំពីដីឥដ្ឋ	៣៦៩១

-ដាក់ឈ្មោះរោងចក្រ ៖ *"វីណាកូមិន្ទ ឫទ្ធី ខមភេនី អិលធីឌី (VINACOMIN RETHTHY COMPANY LTD)"*

-ទីតាំងរោងចក្រ ៖ *ភូមិមនោរម្យ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមរាល់កាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេសដែលត្រូវបាន កំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មាន ជំនាញបច្ចេកទេស មិនអាចចូល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋាន ឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាម បទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការ ចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឲ្យបានបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

អ៊ិត-ប្រាំង

កន្លែងទទួល:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តព្រះសីហនុ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ : ១.៨៧.៩៩...សរ. សក.

រាជធានីភ្នំពេញ. ថ្ងៃទី០៤ ខែមីនា ឆ្នាំ ២០១០.

សេចក្តីសម្រេច
ស្តីពី
ការដាក់អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់អោយស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- យោងតាមការចាំបាច់របស់ក្រសួង។

សម្រេច

ប្រការ ១.-

ត្រូវបានប្រគល់សិទ្ធិជូនប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ដែលជាសមាជិកគណៈកម្មការសម្របសម្រួលអចិន្ត្រៃយ៍ អោយគ្រប់គ្រងផ្ទាល់លើអង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ដែលស្ថិតក្នុងដែនដីរាជធានី ខេត្តរបស់ខ្លួន ជំនួសមុខអោយគណៈកម្មការសម្របសម្រួលអចិន្ត្រៃយ៍។

ប្រការ ២.-

ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ត្រូវគ្រប់គ្រងអង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ តាមការបញ្ជាណែនាំរបស់ប្រធានគណៈកម្មការសម្របសម្រួលអចិន្ត្រៃយ៍ ស្របតាមទិសដៅ និងគោលការណ៍ដាក់ចេញរបស់ប្រធានគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់។

ប្រការ ៣.-

ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន ត្រូវធ្វើបញ្ជីសារពើភណ្ឌ និងគ្រប់គ្រងរាល់ទ្រព្យសម្បត្តិរបស់ស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ក្នុងរាជធានី ខេត្តរបស់ខ្លួន ព្រមទាំងជញ្ជីងចល័តទាំងអស់ដែលមាន ហើយត្រូវរាយការណ៍ជូនប្រធានគណៈកម្មការសម្របសម្រួលអចិន្ត្រៃយ៍ និងអគ្គនាយកសាធារណការ។

ប្រការ ៤.-

អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ មានភារកិច្ច៖

- ធ្វើរបាយការណ៍ការងាររបស់ខ្លួនជាប្រចាំរៀងរាល់ថ្ងៃ ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស ឆ្នាំ ជូនទៅប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនដែលគ្រប់គ្រងអង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន ត្រូវធ្វើរបាយការណ៍បូកសរុបសកម្មភាពនៃស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ទាំងអស់ ជូនប្រធានគណៈកម្មការសម្របសម្រួលអចិន្ត្រៃយ៍ អភិបាលរាជធានី អភិបាលខេត្ត តាមការកំណត់។

ប្រការ ៥.-

ក្នុងករណីជញ្ជីងមានដំណើរការមិនប្រក្រតី ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនត្រូវរាយការណ៍ និងសុំអន្តរាគមន៍ពីអគ្គសាធារណការ ដើម្បីអោយក្រុមបច្ចេកទេសចុះទៅជួសជុលបន្ទាន់។

ប្រការ ៦.-

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយកសាធារណការ អគ្គនាយកដឹកជញ្ជូន អគ្គាធិការ គណៈកម្មការសម្របសម្រួលអចិន្ត្រៃយ៍ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ត្រាំ អ៊ីវតឹក

កន្លែងទទួល៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ខុទ្ទកាល័យឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
- ខុទ្ទកាល័យឯកឧត្តម ស៊ឹម កា ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទីចាត់ការអាជ្ញាធរអាកាសចរស៊ីវិល
- សាលារាជធានី ខេត្ត
- ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ៧៦១០ ស.អ.យ.

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១០

ប្រកាស

ស្តីពីការបង្កើតសាលាជាតិសង្គមកិច្ច

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញការចាំបាច់របស់ក្រសួង

សម្រេច

ប្រការ ១ .-

ត្រូវបានបង្កើត **សាលាជាតិសង្គមកិច្ច** ជាអង្គភាពចំណុះនាយកដ្ឋានរដ្ឋបាល និងបុគ្គលិកនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដែលមានទីតាំងបណ្តោះអាសន្ននៅអគារឡូតិ៍លេខ ៣ ផ្លូវ ៥៥ ហៅផ្លូវលេង្គា សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ឧបសម្ព័ន្ធ ២ .-

សាលាជាតិសង្គមកិច្ច មានតួនាទី និងភារកិច្ច :

- រៀបចំទីតាំងអគារសម្រាប់សាលា

-បំពាក់គ្រឿងបរិក្ខារ

-រៀបចំយុទ្ធសាស្ត្រសម្រាប់រយៈពេលខ្លី មធ្យម និងវែង

-រៀបចំរចនាសម្ព័ន្ធរបស់សាលា

-រៀបចំកម្មវិធីសិក្សា

-រៀបចំជ្រើសរើសគ្រូ បុគ្គលិក និងផ្តល់ជំនាញបន្ថែម

-រៀបចំដំណើរការបើកវគ្គបណ្តុះបណ្តាលមុខជំនាញសង្គមកិច្ចតាមកម្រិត ដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ក្រសួង ។ ជំហានដំបូងសាលាជាតិសង្គមកិច្ច ត្រូវបន្តបើកវគ្គបណ្តុះបណ្តាលដែលបានរៀបរយរួចមកហើយ ដូចជាវគ្គ :

-សេវាសង្គមកិច្ចមូលដ្ឋាន BSST

-សេវាសង្គមកិច្ចជំនាញ PSST

-គ្រប់គ្រងសេវាសង្គមកិច្ច MSST

-ធ្វើការវាយតម្លៃកម្រិតបណ្តុះបណ្តាលជំនាញសង្គមកិច្ចដើម្បីចាត់ថ្នាក់កម្រិតសញ្ញាបត្រជូនដល់សិក្ខាកាមដោយមានការទទួលស្គាល់ពីក្រសួងអប់រំយុវជន និងកីឡា

-លើកគម្រោងបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម វែង សម្រាប់មុខជំនាញសង្គមកិច្ច និងមុខជំនាញបច្ចេកទេសរបស់សាលាក្រោមឱវាទ

-ធ្វើការសិក្សា ចងក្រងឯកសារ ដើម្បីរៀបចំឈានពីសាលាជាតិសង្គមកិច្ច បង្កើតទៅជា **វិទ្យាស្ថានជាតិសង្គមកិច្ច** ជាសាកលវិទ្យាល័យដែលមានមហាវិទ្យាល័យសង្គមកិច្ច មហាវិទ្យាល័យបច្ចេកទេសផលិតអវៈយវៈសិប្បនិម្មិតនិងរណប និងមហាវិទ្យាល័យផ្សេងៗទៀតតាមមុខជំនាញរបស់ក្រសួង និងតាមលក្ខខណ្ឌតិកៈគតិយុត្តនៃការបង្កើតគ្រឹះស្ថានសាធារណៈ

-ធ្វើការបណ្តុះបណ្តាល និង វិក្រឹត្យការដល់អ្នកបច្ចេកទេសក្លាយជាគ្រូ ដើម្បីបង្កើនទាំងបរិមាណនិងគុណភាពស្រប តាមសំណូមពរនៃសេចក្តីត្រូវការរបស់សាលាព្រមទាំងបណ្តុះបណ្តាលជំនាញបន្តប្រកបដោយគុណភាព ដោយផ្តល់ជាវិញ្ញាបនបត្រ និងសញ្ញាបត្រ

-ធ្វើការបណ្តុះបណ្តាលជំនាញទាក់ទងនឹងការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ច្បាប់ស្តីពីស៊ុំកូនអន្តរប្រទេស ច្បាប់ស្តីពីយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ និងច្បាប់ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងវិស័យសង្គមកិច្ចជូនដល់ភ្នាក់ងារសង្គមកិច្ចជាមន្ត្រីរាជការក្របខណ្ឌរបស់ក្រសួង និង បុគ្គលិកស្ម័គ្រចិត្តរបស់អង្គការមនុស្សធម៌ជាតិ អន្តរជាតិ ដែលត្រូវបានក្រសួងចាត់តាំង ឬដែលបានស្ម័គ្រចិត្តចូលរួមក្នុងសេវាសង្គមកិច្ច ឬសិស្ស និស្សិតគ្រប់ប្រភេទ

-រៀបចំលិខិតបញ្ជាក់ការសិក្សាជូនដល់ភ្នាក់ងារ បុគ្គលិក និងសិស្ស និស្សិតទាំងនោះ

-រៀបចំសិក្ខាសាលា សន្និសីទផ្សេងៗតាមសំណូមពរសង្គម

-ធ្វើការសិក្សាស្រាវជ្រាវកម្មវិធីសិក្សា ខ្លឹមសារសិក្សា វិធីសាស្ត្របង្រៀន ចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រជាភាសាខ្មែរ និងភាសាបរទេសឱ្យបានសមស្របតាមលក្ខណៈភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ប្រើប្រាស់ និងសម្រាប់ផ្សព្វផ្សាយទូទៅ

-ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងស្ថាប័ននានាក្នុងគោលបំណងកៀរគរជំនួយថវិកា ធនធានបច្ចេកទេស គួបផ្សំជាមួយថវិកាជាតិធ្វើឱ្យកាន់តែប្រសើរដល់ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេស ដើម្បីលើកកម្ពស់គុណភាពការបណ្តុះបណ្តាលឯកទេសនៅក្នុងសាលាជាតិសង្គមកិច្ច

-ធ្វើការទំនាក់ទំនង និងសិក្សាស្រាវជ្រាវផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមកជាមួយសាលាសង្គមកិច្ចនៅក្នុងតំបន់ជាពិសេសក្នុងអាស៊ាន និងសកលលោក

-លើកគម្រោងថវិកាជូនក្រសួងសម្រាប់ដំណើរការប្រចាំឆ្នាំ ប្រាក់គរុកោសល្យសម្រាប់គ្រូបង្រៀន និងប្រាក់ឈ្នួលសម្រាប់ជួលគ្រូបង្រៀន

-កសាងមូលដ្ឋានផែនការសម្ភារៈ កសាងប្រភពថវិកាតាមរយៈការបណ្តុះបណ្តាល និងសេវាកម្មបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន សាស្ត្រាចារ្យសម្រាប់សាលាដើម្បីអភិវឌ្ឍសាលាឱ្យស្របតាមការរីកចម្រើន និងតម្រូវការរបស់ព្រះរាជាណាចក្រកម្ពុជា

-ធ្វើការកំណត់លក្ខខណ្ឌ លក្ខណៈសម្បត្តិរបស់បេក្ខជន និងដំណើរការប្រឡងជ្រើសរើសសិស្សនិស្សិតឱ្យចូលរៀន ប្រឡងចេញ វាយតម្លៃការសិក្សាឱ្យបានត្រឹមត្រូវតាមគោលការណ៍ និងប្រកបដោយតម្លាភាព

-គ្រប់គ្រងសាលាបណ្តុះបណ្តាលមុខជំនាញបច្ចេកទេសទាំងអស់ ដែលបច្ចុប្បន្នកំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងនៅរដ្ឋបាលថ្នាក់កណ្តាល ពង្រឹងរចនាសម្ព័ន្ធដើម្បីឈានទៅប្រែក្លាយសាលាទាំងនេះទៅជាមហាវិទ្យាល័យចំណុះវិទ្យាស្ថានជាតិសង្គមកិច្ច ឬសកលវិទ្យាល័យសង្គមកិច្ចកិច្ច ដូចជា :

-សាលាបច្ចេកទេសផលិតឧបករណ៍សិប្បនិម្មិត និងរណប

-សាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការតៀនឃ្លាំង

-សាលាបណ្តុះបណ្តាលវិជ្ជាជីវៈភ្នំពេញថ្មី

-គ្រប់គ្រងមន្ត្រីរាជការ និយោជិត កម្មករ និស្សិត គ្រូបង្រៀន សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិរបស់សាលា

-គ្រប់គ្រង ចលនៈ អចលនៈទ្រព្យរបស់សាលា

-ធ្វើរបាយការណ៍រាល់សកម្មភាពសិក្សាជូនក្រសួង ប្រចាំឆមាសនីមួយៗ

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន ។

ប្រការ ៣.-

រចនាសម្ព័ន្ធរបស់សាលាជាតិសង្គមកិច្ច រួមមាន :

-សាលាបណ្តុះបណ្តាលជំនាញសង្គមកិច្ច

-សាលាបច្ចេកទេសផលិតឧបករណ៍សិប្បនិម្មិត និងរណប

-សាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការគៀនឃ្លាំង

-សាលាបណ្តុះបណ្តាលវិជ្ជាជីវៈភ្នំពេញថ្មី

ប្រការ ៤.-

ការដឹកនាំ និងគ្រប់គ្រងសាលាជាតិសង្គមកិច្ច

ក-ការដឹកនាំ

ចំពោះមុខនេះ ត្រូវបានចាត់តាំងក្រុមប្រឹក្សាភិបាលបណ្តោះអាសន្នមួយ ដើម្បីដឹកនាំអនុវត្តភារកិច្ចដូចមានចែងក្នុងប្រការ ២ ខាងលើ ជាពិសេសការរៀបចំឯកសារប្រែក្លាយសាលាជាតិសង្គមកិច្ចឱ្យទៅជាវិទ្យាស្ថានជាតិសង្គមកិច្ច

-រៀបចំឱ្យមានការទទួលស្គាល់ជាផ្លូវការពីស្ថាប័នជាតិ ស្តីពីការអភិវឌ្ឍធនធានមនុស្សលើបទដ្ឋានជាតិ និងអន្តរជាតិ

-រៀបចំសាលាឱ្យក្លាយជាសមាជិកសាលាសង្គមកិច្ចក្នុងក្របខ័ណ្ឌអាស៊ាន ។

សមាសភាពនៃក្រុមប្រឹក្សាភិបាលបណ្តោះអាសន្ន មានដូចខាងក្រោម :

១-ឯកឧត្តម	សយ	ស៊ីផុន	រដ្ឋលេខាធិការ	ប្រធាន
២-លោកជំទាវ ច័ន្ទ		ហាភីនវឌ្ឍី	អនុរដ្ឋលេខាធិការ	អនុប្រធាន
៣-ឯកឧត្តម	មុំ	ប៊ុនថន	អនុរដ្ឋលេខាធិការ	អនុប្រធាន
៤-លោក	យូ	សុទ្ធី	អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ	អនុប្រធាន
៥-លោក	សាំណែត	វឌ្ឍនា	អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកទេស	អនុប្រធាន
៦-លោក	យូ	វីរៈ	អនុប្រធាននាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា	អនុប្រធាន
៧-លោក	ឃួន	ឡាំនិច	ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក	សមាជិក
៨-លោក	ញ៉េប	ចាន់រលោ	ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៩-លោក	ប៉ៃ	សំបួរ	អនុប្រធាននាយកដ្ឋានសោធននិវត្តន៍	សមាជិក
១០-លោក	មួល	ឈន	នាយកមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មគៀនឃ្លាំង	សមាជិក
